# មុខវិជ្ជា៖
# គីមីអសរីរាង្គ

## កញ្ចប់សមត្ថភាពទី ១
## ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ

## ការពណ៌នាអំពីមុខវិជ្ជា

មុខវិជ្ជានេះ នឹងផ្តោតលើបញ្ញត្តិមួយចំនួន ដែលទាក់ទងនឹងបញ្ញត្តិទូទៅរបស់គីមីអសរីរាង្គ ទម្រង់ អាតូម តារាងខួបនៃធាតុគីមី ទម្រង់ម៉ូលេគុលនិងការចងសម្ព័ន្ធក្នុងម៉ូលេគុល និងលក្ខណៈនៃសមា សធាតុអសរីរាង្គ។ យើងក៏នឹងសិក្សាអំពីគោលការណ៍យោបកលោហៈ លក្ខណៈរបស់លោហៈ លក្ខណៈរបស់លោហៈឆ្លង អលោហៈមួយចំនួន និងការងារពិសោធន៍។

**លទ្ធផលសិក្សារំពឹងទុក**

*ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹង៖*

CLO1.ពិពណ៌នាអំពីរូបធាតុ ភាវៈរូបរបស់រូបធាតុ បញ្ញត្តិនានាដែលមាននៅក្នុងគីមីអសរីរាង្គ។

CLO2. បង្ហាញពីវិធីថ្លឹងសមីការតាងប្រតិកម្មគីមី សរសេរនិមិត្តសញ្ញា និងរូបមន្តគីមីឲ្យត្រឹមត្រូវ។

CLO3. ពន្យល់គោលការណ៍និងច្បាប់នានា។

CLO4. ទទួលស្គាល់ (i) គោលគំនិតអាស៊ីត-បាសរបស់ Lewis និង (ii) លក្ខខណ្ឌនិងដែន កំណត់នៃអាស៊ីតរឹង និងទន់។

CLO5. រៀបចំផែនការអនុវត្ត និងរៀបចំឯកសារនៅក្នុងកំណត់ហេតុមន្ទីរពិសោធន៍ និងដោយ ផ្ទាល់មាត់ និង/ឬជាលាយលក្ខណ៍អក្សរ គណនីសម្រាប់លទ្ធផលពិសោធន៍។

CLO6. រៀបចំផែនការ អនុវត្តការវាយតម្លៃហានិភ័យ និងសុវត្ថិភាពជាមូលដ្ឋាន ហើយអាចធ្វើការ ប្រកបដោយសុវត្ថិភាពនៅក្នុងមន្ទីរពិសោធន៍

CLO7. គណនីសម្រាប់ផលិតកម្មឧស្សាហកម្ម និងការប្រើប្រាស់សមាសធាតុអសរីរាង្គសំខាន់ៗ។

CLO8. ផ្តល់ឧទាហរណ៍នៃលក្ខណៈនៃសារធាតុពីទស្សនៈ សង្គម - បរិស្ថាន ការប្រើប្រាស់ និងធនធាន។

**វាយតម្លៃសិក្សា**

*ដើម្បីបំពេញគ្រប់លក្ខខណ្ឌបញ្ចប់ការសិក្សាមុខវិជ្ជានេះ អ្នកសិក្សាត្រូវ*

១. វត្តមានចូលសិក្សា ១០%

២. ការចូលរួមសកម្មភាពសិក្សា ២០%

៣. ការវាយតម្លៃកំឡុងពេលសិក្សា ៣០%

៤. ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សា ៤០%

**កិច្ចការត្រូវអនុវត្តដើម្បីសម្រេចលទ្ធផលសិក្សារំពឹងទុក៖**

*ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹង៖*

កិច្ចការទី ១៖ តេស្ត Google Form

កិច្ចការទី ២៖ កិច្ចការឆ្លុះបញ្ចាំង

# **អារម្ភកថា**

វិស័យអប់រំ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកថាជាវិស័យអាទិភាព និងត្រូវបានធ្វើកំណែទម្រង់ជាប្រចាំ ឆ្ពោះទៅលើកកម្ពស់គុណភាពនៃការសិក្សានៅគ្រប់កម្រិត។ ក្រសួងអប់រំ យុវជន និងកីឡាបាននិងកំពុងពិនិត្យឡើងវិញកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន និងជំរុញកំណែទម្រង់សាលារៀននៅគ្រប់កម្រិត ដើម្បីធានាថាសាលារៀនមានដំណើរការប្រកបដោយប្រសិទ្ធភាពសម្រាប់ការសិក្សារៀនសូត្ររបស់សិស្ស និងផ្តល់ដល់សិស្សនូវវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា ឆ្លើយតបបានទៅតាមតម្រូវការទីផ្សារការងារ និងចូលរួមចំណែកពេញលេញក្នុងការអភិវឌ្ឍសហគមន៍ និងប្រទេសជាតិ ឈានឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និងឆ្នាំ២០៥០ ។

ជាផ្នែកមួយនៃកំណែទម្រង់ការបណ្តុះបណ្តាលគ្រូបង្រៀន ឆ្ពោះទៅលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនតាមរយៈគម្រោងកែលម្អការអប់រំចំណេះទូទៅ ក្រសួងបានរៀបចំ "ក្របខណ្ឌកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលបរិញ្ញាបត្រអប់រំ វិជ្ជាជីវៈគ្រូបង្រៀន ឯកទេសទាំង ៦ (អក្សរសាស្ត្រខ្មែរ, គណិតវិទ្យា, គីមីវិទ្យា, ជីវវិទ្យា, រូបវិទ្យា, ប្រវត្តិវិទ្យា) ដើម្បីប្រើប្រាស់ក្នុងកម្មវិធីវិក្រឹតការគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀននៅតាមសាលារៀនចំណេះទូទៅ។ ក្របខណ្ឌកម្មវិធីសិក្សានេះជាឯកសាររស់ ដែលនឹងអាចមានការកែសម្រួលទៅតាមស្ថានភាពជាក់ស្តែង ជាពិសេសនៅដំណាក់កាលអន្តរកាលនៃការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន។

ក្រសួងមានជំនឿយ៉ាងមុតមាំ លើប្រសិទ្ធភាពនៃការអនុវត្តក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលនេះ ដែលនឹងនាំគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀននៅគ្រប់ភូមិសិក្សា សម្រេចបានគោលដៅអប់រំ ដែលនឹងចូលរួមចំណែកក្នុងការសម្រេចបានចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា។

ខ្ញុំសូមថ្លែងអំណរគុណ និងសូមកោតសរសើរដ៏ស្មោះចំពោះ ឯកឧត្តមបណ្ឌិតសភាចារ្យនាយកគម្រោង និងក្រុមការងារគម្រោងកែលម្អការអប់រំចំណេះទូទៅ ជាពិសេសក្រុមការងារនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញដែលបានខិតខំផលិតឯកសារក្របខណ្ឌកម្មវិធីសិក្សានេះឡើង សម្រាប់ប្រើប្រាស់ក្នុងការបណ្តុះបណ្តាលក្នុងគម្រោងកែលម្អការអប់រំចំណេះទូទៅ។

ថ្ងៃ ច័ន្ទ ៦ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០២៣
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# គណៈកម្មការ

## ១. គណៈកម្មការគ្រប់គ្រង

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិតសភាចារ្យ | **ហង់ជួន ណារ៉ុន** | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
| ២. ឯកឧត្តមបណ្ឌិតសភាចារ្យ | **ណាត ប៊ុនរឿន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ៣. ឯកឧត្តមបណ្ឌិត | **ជេត ជាលី** | សាកលវិទ្យាធិការសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៤. លោកបណ្ឌិត | **ឈុន ហុក** | សាកលវិទ្យាធិការរង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៥. លោក | **ម៉ាល់ ដែល** | សាកលវិទ្យាធិការរង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៦. លោកបណ្ឌិត | **សំអោ អក្ខរាតន៍** | អគ្គនាយករង អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ |
| ៧. លោក | **ព្រីង មរកត** | ប្រធាននាយកដ្ឋានមធ្យមសិក្សា |

## ២. គណៈកម្មការនិពន្ធ រៀបរៀង និងចងក្រង

| | | |
|---|---|---|
| ១. លោកបណ្ឌិត | **សុខ សុត្រ** | ព្រឹទ្ធបុរសមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ២. លោក | **មាក ភាមេរ៉ាន** | ព្រឹទ្ធបុរសមហាវិទ្យាល័យវិទ្យាសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៣. លោកបណ្ឌិត | **ជ័យ ចាន់រឿន** | ព្រឹទ្ធបុរសរងមហាវិទ្យាល័យវិទ្យាសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៤. លោកបណ្ឌិត | **ម៉ម សុជាត** | ព្រឹទ្ធបុរសរងមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៥. លោក | **សុត ខសាល** | ប្រធានដេប៉ាតឺម៉ង់សិក្សាអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៦. លោកបណ្ឌិត | **ឃុន ឥមលាង** | ប្រធានដេប៉ាតឺម៉ង់រូបវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៧. លោកស្រីបណ្ឌិត | **ស៊ូ កល្យាណ** | អនុប្រធានដេប៉ាតឺម៉ង់រូបវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៨. លោក | **ហង់ ស៊ីម** | សាស្ត្រាចារ្យដេប៉ាតឺម៉ង់រូបវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៩. លោក | **ដួង ប៉េងអាន** | អ្នកសម្របសម្រួលកម្មវិធីមធ្យមសិក្សា មហាវិទ្យាល័យអប់រំ |
| ១០. កញ្ញា | **ហុង ខ្សៃហៀក** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ១១. លោក | **សើ ពន្លក** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |

## ៣. គណៈកម្មការត្រួតពិនិត្យ និងកែលម្អ

| | | |
|---|---|---|
| ១. លោកបណ្ឌិត | **សំអោ អក្ខរាតន៍** | អគ្គនាយករង អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ |
| ២. លោក | **ព្រីង មរកត** | ប្រធាននាយកដ្ឋានមធ្យមសិក្សា |
| ៣. លោក | **ថៅ ប៉េងឡុង** | ប្រធាននាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹត្យការ |
| ៤. ឯកឧត្តមបណ្ឌិត | **សិត សេង** | នាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ |
| ៥. លោកបណ្ឌិត | **ឈុក ច័ន្ទឆាយា** | អនុប្រធាននាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹត្យការ |
| ៦. លោក | **កែវ សារ៉ាត់** | ទីប្រឹក្សាបច្ចេកទេសគម្រោងកែលម្អការអប់រំចំណេះទូទៅ |

## ៤. ការរីកុំព្យូទ័រ

| | | |
|---|---|---|
| ១. លោក | **ម៉ៅ ម៉ាអ៊ី** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |

២. លោក **ឌុន សំណាង** បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

# លទ្ធផលសិក្សារំពឹងទុក

ការសិក្សាក្នុងកម្មវិធីនេះគឺផ្តោតលើប្រតិបត្តិជាក់ស្តែងរបស់អ្នកសិក្សាដែលអនុវត្តផ្ទាល់នៅសាលារៀន។ ទាំងអ្នកសិក្សា និងសិស្ស (ដែលអ្នកសិក្សានឹងធ្វើការជាមួយផ្ទាល់) ចាំបាច់មាន (១) បំណិនចិត្តសង្គម (២) បំណិនពុទ្ធិ និង (៣) បំណិនបច្ចេកទេស ជាមូលដ្ឋាន (ដូចក្នុងរូបទី១)។ កញ្ចប់សមត្ថភាពទាំងបីខាងដើមនឹងជួយឱ្យអ្នកសិក្សា អភិវឌ្ឍបំណិនចិត្តសង្គម បំណិនពុទ្ធិ និងពង្រឹងសមត្ថភាពផ្នែក (ក)ការសម្រេចចិត្ត ទំនាក់-ទំនង សេចក្តីអំណត់ ទឹកចិត្តអាណិតអាសូរ និងការគ្រប់គ្រងខ្លួនឯង ថែមទាំងអាចអនុវត្តការបង្រៀនមុខវិជ្ជា ឯកទេសគីមីប្រកបដោយវិជ្ជាជីវៈ និងនវានុវត្តន៍ដោយប្រើប្រាស់ឧត្តមានុវត្តន៍ផ្សេងៗ (ខ) ការដោះស្រាយបញ្ហា និង ការរៀបចំនិងការចាត់ចែង (គ) បច្ចេកទេសកម្រិតមធ្យម និងកម្រិតខ្ពស់។




*រូបភាពទី១*
*ប្រភព៖ WDR2018 (p.103)*

ដោយឡែក សម្រាប់អ្នកសិក្សាកម្មវិធីនេះផ្ទាល់ នឹងទទួលបាន៖

**(១) ចំណេះដឹងឯកទេសគីមីកម្រិតបរិញ្ញាបត្រ**

- មុខវិជ្ជា គីមីរូប
- មុខវិជ្ជា គីមីសរីរាង្គ
- មុខវិជ្ជា គីមីវិភាគ
- មុខវិជ្ជា គីមីអសរីរាង្គ
- មុខវិជ្ជា ស្ថិតិវិភាគសម្រាប់អ្នកគីមី
- ចិត្តសង្គម ភាពជាអ្នកដឹកនាំ និងគ្រប់គ្រង

- ❖ សន្លឹកកិច្ចការស្វ័យសិក្សានៅមធ្យមសិក្សា
- ❖ ការសរសេរ និងការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេសគីមី

**(២) ចំណេះដឹងវិធីគរុកោសល្យ សាស្ត្របង្រៀន និងការអប់រំគីមីកម្រិតមធ្យមសិក្សា**

- ❖ វិធីសាស្ត្របង្រៀន
- ❖ វិធីសាស្ត្រវាយតម្លៃ
- ❖ ការស្រាវជ្រាវប្រតិបត្តិ
- ❖ ប្រឹក្សាគរុកោសល្យ
- ❖ បំណិនឌីជីថលសម្រាប់ការអប់រំ

**(៣) ហ្វឹកហាត់កម្មសិក្សាគរុកោលស្យ និងការអនុវត្តជាក់ស្តែង**

- ❖ អនុវត្តស្តង់ដា នៃយុទ្ធសាស្ត្រសហគមន៍សាលារៀន
- ❖ ការអនុវត្តកម្មវិធីស្វ័យសិក្សាគីមី ពីទីថ្នាក់៧-ទី១២
- ❖ របាយការណ៍នៃការអនុវត្តស្តង់ដា នៃយុទ្ធសាស្ត្រសហគមន៍សាលារៀន

លទ្ធផលសិក្សារំពឹងទុកសម្រាប់បរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀននេះ ត្រូវបានកំណត់ដូចខាងក្រោម៖

***វិជ្ជាសម្បទា***

PLO1- ពន្យល់អំពីទ្រឹស្តី និងគោលការណ៍នៃការអប់រំក្នុងបរិបទសកលលោក និងបរិបទប្រទេសដើម្បីឆ្លុះបញ្ចាំងទៅនឹងការអនុវត្តជាក់ស្តែងនៃការបង្រៀន។

PLO2- បកស្រាយអំពីដំណើរការអនុវត្តកិច្ចការសម្រាប់ការបង្វឹកលើការរៀបចំកម្មវិធីសិក្សា និងការបង្រៀនគីមីប្រកបដោយប្រសិទ្ធភាព។

***បំណិនសម្បទា***

PLO3- អនុវត្តបំណិនចិត្តសង្គម និងបច្ចេកវិទ្យាឌីជីថលសម្រាប់បង្កើនការប្រាស្រ័យទាក់ទងគ្នាក្នុងការងារ និងជីវភាពប្រកបដោយវិជ្ជាជីវៈ និងដោះស្រាយបញ្ហាប្រកបដោយភាពច្នៃប្រឌិត និងការទទួលខុសត្រូវ។

PLO4- បង្កើតគន្លឹះ និងទម្រង់សម្រាប់ដឹកនាំ និងគ្រប់គ្រងការបង្រៀនដោយផ្តោតលើផលសម្រេចនៃការសិក្សារបស់សិស្សឆ្ពោះទៅរកស្តង់ដាសាលារៀនមានប្រសិទ្ធភាព និងនិរន្តភាពសាលារៀនតាមរយៈការសិក្សា ការអនុវត្តជាក់ស្តែង និងការស្រាវជ្រាវ។

PLO5- អនុវត្តការងារអភិវឌ្ឍកម្មវិធីសិក្សា ការរៀននិងការបង្រៀនគីមី និងការសិក្សាបែបគម្រោងភ្ជាប់នឹងបំណិនរកចំណូលសម្រាប់សាលារៀនប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

***ចរិយាសម្បទា***

PLO6- អភិវឌ្ឍឥរិយាបថវិជ្ជមាន និងវប្បធម៌រៀនពេញមួយជីវិតសម្រាប់បំពេញការងារ និងទាក់ទងជាមួយអ្នកដទៃប្រកបដោយគុណតម្លៃ មនុស្សធម៌ សាមគ្គីភាព និងការចែករំលែកគ្នា។

PLO7- បង្កើត/បង្ហាញការដឹកនាំបណ្ដាញសម្រាប់កសាងភ្នាក់ងារពង្រីកឧត្តមានុវត្តន៍សម្រាប់ការរៀន និងការបង្រៀន។

សម្គាល់៖ Program Learning Outcome (PLO) លទ្ធផលសិក្សាកម្មវិធីអប់រំ

# កញ្ចប់សមត្ថភាព និង រចនាសម្ព័ន្ធកម្មវិធីសិក្សា

កម្មវិធីបរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀននេះ តម្រូវឱ្យអ្នកសិក្សាសិក្សាចំនួន ៦៣ ក្រេឌីតដែលមានរយៈពេលចន្លោះពី ១២ ទៅ ១៨ខែ។ ការសិក្សានិងធ្វើឡើងតាមរយៈការរៀនពីចម្ងាយ (ភាគច្រើនចន្លោះពី ៦០% ទៅ ៧០%) និងសិក្សាផ្ទាល់នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញនិង សាលាហាត់ការ (ភាគតិចចន្លោះពី ៤០% ទៅ ៣០%)។ ការសិក្សាផ្ដោតលើបណ្ដុំមុខវិជ្ជា (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៣៦ ក្រេឌីត) (២)ចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និងការអប់រំមធ្យមសិក្សា (១២ (+៣) ក្រេឌីត) (៣) ហ្វឹកហាត់កម្មសិក្សាគរុកោសល្យ និងការអនុវត្តជាក់ស្ដែង(១២ ក្រេឌីត)។ បន្ថែមពីលើនេះទៀតអ្នកសិក្សាត្រូវអនុវត្តខ្លឹមសារមេរៀនដែលបានសិក្សាក្នុងកម្មវិធីនៅសាលាសាមីផ្ទាល់តែម្ដងដោយមានការណែនាំពីគ្រូបង្វឹក ប្រឹក្សាគរុកោសល្យ គ្រូបង្រៀននៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងមន្ត្រីអប់រំមកពីនាយកដ្ឋានជំនាញផ្សេងៗរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលមានបទពិសោធន៍អនុវត្តជាក់ស្ដែងកន្លងមក ។

| បណ្ដុំមុខវិជ្ជា | ចំនួនក្រេឌីត |
|---|---|
| (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៦០%) | ៣៦ |
| (២)ចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និងការអប់រំមធ្យមសិក្សា (២០%) | ១២ (+៣) |
| (៣)ហ្វឹកហាត់កម្មសិក្សាគរុកោសល្យ និងការអនុវត្តជាក់ស្ដែង (២០%) | ១២ |
| សរុប | ៦០ (+៣) |

***សម្គាល់៖*** *សម្រាប់កញ្ចប់សមត្ថភាពចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និងការអប់រំមធ្យមសិក្សាបានបន្ថែមមុខវិជ្ជាបំណិនឌីជីថលសម្រាប់ការអប់រំចំនួន ៣ក្រេឌីត*

## លក្ខណៈទូទៅនៃមុខវិជ្ជាសិក្សា

មុខវិជ្ជាសិក្សាសម្រាប់កម្រិតបរិញ្ញាបត្រអប់រំនេះនឹងជួយឱ្យអ្នកសិក្សាបំពេញកញ្ចប់សមត្ថភាពដូចខាងក្រោម ដើម្បីឆ្លើយតបនឹងលទ្ធផលសិក្សាកម្មវិធីអប់រំហើយឱ្យអ្នកសិក្សាមានសមត្ថភាពសម្រាប់បំពេញការងារប្រកបដោយវិជ្ជាជីវៈ។

| បណ្ដុំមុខវិជ្ជា | មុខវិជ្ជាសិក្សា | ក្រេឌីត |
|---|---|---|
| (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៦០%) | មុខវិជ្ជា គីមីរូប | ៣ |
| | មុខវិជ្ជា គីមីសរីរាង្គ | ៣ |
| | មុខវិជ្ជា គីមីវិភាគ | ៣ |
| | មុខវិជ្ជា គីមីអសរីរាង្គ | ៣ |
| | មុខវិជ្ជា ស្ថិតិវិភាគសម្រាប់អ្នកគីមី | ៣ |
| | ការអនុវត្តសន្លឹកកិច្ចការឯកទេសគីមីសម្រាប់សិស្សស្វ័យសិក្សាកម្រិត១ (ចងចាំ) | ៣ |

| | | |
|---|---|---|
| | ការអនុវត្តសន្លឹកកិច្ចការឯកទេសគីមីសម្រាប់សិស្សស្វ័យសិក្សាកម្រិត២ (យល់ដឹង) | ៣ |
| | សន្លឹកកិច្ចការឯកទេសគីមីសម្រាប់សិស្សស្វ័យសិក្សាកម្រិត៣ (ហ្វឹកហាត់) | ៣ |
| | សន្លឹកកិច្ចការឯកទេសគីមីសម្រាប់សិស្សស្វ័យសិក្សាកម្រិត៤ (វាយតម្លៃ) | ៣ |
| | ការសរសេរ និងការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស | ៩ |
| (៣)ចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និង ការអប់រំមធ្យមសិក្សា (២០%) | វិធីសាស្ត្របង្រៀន បត់បែនតាមសមត្ថភាពសិស្ស និងទស្សនទានអប់រំថ្មីៗ | ៣ |
| | ប្រឹក្សា និងហ្វឹកហ្វឺនគរុសល្យលើយុទ្ធសាស្ត្រសហគមន៍សាលារៀន | ៣ |
| | មូលដ្ឋានគ្រឹះវង្វាយតម្លៃអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះនៃការស្រាវជ្រាវប្រតិបត្តិ | ៣ |
| | បំណិនឌីជីថលសម្រាប់ការអប់រំ* | ៣ |
| (៤)ហ្វឹកហាត់កម្មសិក្សាគរុកោសល្យ និងការអនុវត្តជាក់ស្តែង (២០%) | ការអនុវត្ត ស្តង់ដាយុទ្ធសាស្ត្រសហគមន៍សាលារៀន (ស្តង់ដាទី១) | ៣ |
| | ការអនុវត្ត ស្តង់ដានៃយុទ្ធសាស្ត្រសហគមន៍សាលារៀន (ស្តង់ដាទី២) | ៦ |
| | របាយការណ៍និងការការពារស្តីពីការអនុវត្តស្តង់ដាយុទ្ធសាស្ត្រសហគមន៍សាលារៀន | ៣ |
| **សរុប** | | **៦៣** |

លំហូរបង្រៀន និងរៀន




## ការវាយតម្លៃលើការសិក្សា

ការវាយតម្លៃលើការសិក្សារបស់អ្នកសិក្សាគឺផ្តោតលើលទ្ធផលសិក្សាជាគោល។ ការវាយតម្លៃលើការសិក្សាមានបីដំណាក់កាលធំៗ គឺ (១) ការវាយតម្លៃលើការសិក្សាមុខវិជ្ជា (២) ការវាយតម្លៃលើការសរសេរឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស និង (៣) ការវាយតម្លៃសរុបដោយពិនិត្យលើការបំពេញគ្រប់លក្ខខណ្ឌសម្រាប់បញ្ចប់ការសិក្សា។

### ៦.៤.១ គោលការណ៍វាយតម្លៃ

គោលការណ៍រួមសម្រាប់ការវាយតម្លៃលើការសិក្សារបស់អ្នកសិក្សាមានដូចតទៅ៖

១) អ្នកសិក្សាតម្រូវឱ្យមានវត្តមានក្នុងការសិក្សាតាមមុខវិជ្ជានីមួយៗ មិនតិចជាង៧០%។ ក្នុងករណីអ្នកសិក្សាមានវត្តមានតិចជាង៧០% នឹងមិនត្រូវបានអនុញ្ញាតឱ្យប្រឡងបញ្ចប់មុខវិជ្ជានោះទេ

២) ក្នុងករណីដែលអ្នកសិក្សាធ្លាក់មុខវិជ្ជាណាមួយក្នុងឆមាស នឹងមិនអនុញ្ញាតឱ្យបន្តការសិក្សាទៅឆ្នាំបន្ទាប់ និងប្រឡងបញ្ចប់ឡើយ

៣) អ្នកសិក្សាទាំងអស់ត្រូវធ្វើកិច្ចការស្រាវជ្រាវសំខាន់ៗតាមមុខវិជ្ជានីមួយៗ និងប្រគល់ជូនគ្រូឧទ្ទេសតាមមុខវិជ្ជាដែលបានកំណត់

៤) អ្នកសិក្សាត្រូវប្រឡងបញ្ចប់ការសិក្សាដែលធ្វើឡើងបន្ទាប់ពីចប់ឆមាសនីមួយៗ តាមការកំណត់ក្នុងកម្មវិធីសិក្សា

៥) អ្នកសិក្សាត្រូវចងក្រងឯកសារវឌ្ឍនភាពនៃកិច្ចការស្នូលរួមមានការហាត់ការ និងកម្មសិក្សាដែលផ្ដោតលើ (ក) សកម្មភាពប្រតិបត្តិ (ខ) លទ្ធផលដែលសម្រេចបាន និង (គ) ការឆ្លុះបញ្ចាំង និងមេរៀនបទពិសោធន៍ និង

៦) អ្នកសិក្សាត្រូវតែជាប់មធ្យមភាគនៃការសិក្សាមុខវិជ្ជានិងការធ្វើកម្មសិក្សា ដើម្បីទទួលការអនុញ្ញាតឱ្យការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស។

### ការផ្ដល់ពិន្ទុ និងប្រព័ន្ធចំណាត់ថ្នាក់

អ្នកសិក្សាអាចទទួលពិន្ទុចាប់ពី 00 ដល់ 100 ទៅតាមការវាយតម្លៃផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងការសិក្សាមុខវិជ្ជា ការបំពេញកម្មសិក្សា និងការសរសេរនិងការការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស។ ពិន្ទុដែលជាប់ត្រូវចាប់ផ្ដើមពីមធ្យមភាគពិន្ទុ 50% ឬពិន្ទុនិទ្ទេស 2.00 ឡើងទៅ។

ពិន្ទុគឺកំណត់ពី 00.00 ដល់ 100 (មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប ឬ Grade Point Average–GPA)។ រូបមន្តគណនារកមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) គឺមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) ស្មើផលបូកសរុបរវាងផលគុណនៃពិន្ទុនិទ្ទេស (Grade Point–P) និងតម្លៃក្រេឌីតដែលត្រូវយកនៃមុខវិជ្ជានីមួយៗ (Attempted Credit Value–C) ចែកនឹងផលបូកសរុបនៃតម្លៃក្រេឌីតដែលត្រូវយកគ្រប់មុខវិជ្ជា។

ប្រព័ន្ធចំណាត់ថ្នាក់កម្មវិធី គឺផ្អែកទៅលើតម្លៃនៃពិន្ទុអតិបរមា 100% និង 50% នៃពិន្ទុអប្បបរមា។ ប្រព័ន្ធដាក់ពិន្ទុនេះ ត្រូវបានបកប្រែទៅជា «ពិន្ទុជានិទ្ទេស» និង «ពិន្ទុជាតម្លៃលេខ» ដូចដែលពិពណ៌នាខាងក្រោម៖

| ពិន្ទុជាភាគរយ% | និទ្ទេស | ពិន្ទុនិទ្ទេស | មូលវិចារណ៍ |
|---|---|---|---|
| 85%-100% | A | 4.00 | ល្អប្រសើរ |
| 80%-84% | B+ | 3.50 | ល្អណាស់ |
| 70%-79% | B | 3.00 | ល្អ |
| 65%-69% | C+ | 2.50 | ល្អបង្គួរ |

| | | | |
|---|---|---|---|
| 50%-64% | C | 2.00 | មធ្យម |
| <49% | F | 1.50 | ធ្លាក់ |

## ៦.៥ គោលការណ៍ប្រតិបត្តិ

ដើម្បីធានានូវការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងភាពស័ក្តិសិទ្ធិ មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញអនុវត្តតាមគោលការណ៍ បទបញ្ញត្តិ និងបទដ្ឋានគតិយុត្តិរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងគោលការណ៍ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានេះដែរ អ្នកសិក្សាម្នាក់ៗ ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងឈរលើស្មារតីស្មោះត្រង់ ទទួលខុសត្រូវខ្ពស់ និងភាពម្ចាស់ការ និងគោលការណ៍សុចរិតភាពនៃការសិក្សា។ សម្រាប់គោលការណ៍សុចរិតភាពនៃការសិក្សា អ្នកសិក្សាម្នាក់ៗ ត្រូវបានវាយតម្លៃលើចំណុចសំខាន់ៗដូចខាងក្រោម៖

### ៦.៥.១ ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយា

ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់អ្នកសិក្សាម្នាក់ៗ ត្រូវបានប្រមូលផ្តុំលើការគោរពវិន័យចាត់តាំង ការមករៀនទៀងទាត់ ការយកចិត្តទុកដាក់ក្នុងការសិក្សា ការខិតខំស្រាវជ្រាវ ការអនុវត្តភារកិច្ច និងស្មារតីសាមគ្គីភាពនៅក្នុងថ្នាក់ ក្នុងគ្រឹះស្ថានសិក្សា និងក្រៅគ្រឹះស្ថានសិក្សា។ ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់អ្នកសិក្សាម្នាក់ៗ ត្រូវបានធ្វើឡើងតាមរយៈយោបល់ឯកភាពពីមតិភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាវិន័យ ដោយផ្អែកលើលក្ខណសម្បត្តិជាក់ស្តែងរបស់អ្នកសិក្សាម្នាក់ៗ និងបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

### ៦.៥.២ ការក្លែងបន្លំឯកសារ

អ្នកសិក្សាដែលក្លែងបន្លំឯកសារ នឹងត្រូវលុបឈ្មោះចេញពីបញ្ជីនិស្សិតដោយស្វ័យប្រវត្តិ ព្រមទាំងទទួលទោសតាមច្បាប់ជាធរមាន។ អ្នកសិក្សាត្រូវចាំថា ការលួចចម្លងស្នាដៃ ការលួចកម្មសិទ្ធិបញ្ញា និងគំនិតរបស់អ្នកដទៃគឺជាបទល្មើសសិក្សាធ្ងន់ធ្ងរដែលអាចឈានដល់ការបញ្ឈប់បុគ្គលដែលប្រព្រឹត្តបទល្មើសពីកម្មវិធី។ ត្រូវសម្រេចឱ្យធ្លាក់ជាស្ថាពរ បើអ្នកសិក្សារូបណាចម្លងដោយផ្ទាល់ពីអ្នកសិក្សាដទៃទៀត ឬប្រភពផ្សេងៗ ឬការប្រើសម្ភារៈ ឬឯកសារផ្សេងទៀត ដែលមិនត្រូវបានអនុញ្ញាតក្នុងការប្រឡង។

### ៦.៥.៣ ឯកសារជំនួយស្មារតី/របាយការណ៍/កិច្ចការស្រាវជ្រាវ

អ្នកសិក្សាត្រូវបង្ហាញនូវសុចរិតភាពនៃការស្រាវជ្រាវរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន ចាប់តាំងពីពេលចូលរៀនរហូតដល់ចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល។ រាល់សំណេរការងារសិក្សាទាំងអស់ មិនត្រូវដកស្រង់គំនិត សរសេរ ឬចម្លងស្នាដៃផ្សេងៗរបស់អ្នកដទៃមកធ្វើជាគំនិត ជាស្នាដៃ ឬជាកម្មសិទ្ធិរបស់ខ្លួនដោយគ្មានការបញ្ជាក់ពីប្រភពច្បាស់លាស់នៃឯកសារយោង ឯកសារពិគ្រោះ ឬការអនុញ្ញាតពីម្ចាស់ប្រភព។

ក្នុងករណីរកឃើញមានការលួចចម្លងស្នាដៃអ្នកដទៃ អ្នកសិក្សានឹងត្រូវប្រឈមមុខចំពោះក្រុមប្រឹក្សាបច្ចេកទេស និងក្រុមប្រឹក្សាវិន័យរបស់មហាវិទ្យាល័យអប់រំ ឬសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយត្រូវទទួល

ពិន័យឱ្យរៀនត្រួតថ្នាក់ ឬអាចត្រូវបញ្ឈប់ពីកម្មវិធីដោយគ្មានសំណងប្រាក់សិក្សាដែលបានបង់រួចហើយ និងមិនមានការចេញលិខិតស្នាមបញ្ជាក់ការសិក្សាអ្វីដែរ។

**សម្គាល់៖** កម្មវិធីបណ្តុះបណ្តាលសូមរក្សាសិទ្ធិក្នុងការកែប្រែការអនុវត្តជាក់ស្តែងឱ្យឆ្លើយតបទៅនឹងវឌ្ឍនភាពការរៀននិងបង្រៀន សមត្ថភាពរៀននិងការអនុវត្តជាក់ស្តែង និង ស្ថានភាពរៀននិងបង្រៀនជាក់ស្តែង ដើម្បីសម្រេចបានលទ្ធផលសិក្សាល្អបំផុត និងសម្រេចស្តង់ដាសហគមន៍សាលារៀននៃគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) ។

មេរៀនទី១

# បញ្ញត្តិទូទៅ

1

# រូបធាតុ

## ល្បាយ

### ល្បាយស្មើសាច់



ទឹកសុទ្ធ



ទឹកអំបិល

### ល្បាយមិនស្មើសាច់



ខ្សាច់+ផង់ដែក

ញែកដោយវិធីរូប



## សារធាតុ

### ធាតុសមាស










### ធាតុទោល










2

**អាតូម ៖**

ជាភាគល្អិតតូចបំផុត បង្កឡើងពីអេឡិចត្រុង និង ណ្វៃយ៉ូ

**អេឡិចត្រុង**

ជាភាគល្អិត មានបន្ទុក $-1$ និងមានម៉ាស $9.1 \times 10^{-31}$Kg

**ណ្វៃយ៉ូ**

ជាផ្នែកមួយនៃអាតូមដែលមានភាគល្អិតរបស់វាគឺ៖

**Proton**

ជាភាគល្អិតដែលមានបន្ទុក $+1$ និងមានម៉ាសស្មើនឹង $1.67 \times 10^{-27}$Kg

**Neutron**

ជាភាគល្អិតមានបន្ទុកសូន្យ និងមានម៉ាសស្មើនឹង $1.67 \times 10^{-27}$Kg

$Na(z = 11, A = 23amu)$

គេថាសូដ្យូមមាន១១ប្រូតុង និង១២ណឺត្រុង

$Ca(z = 20, A = 40$

គេថាកាល់ស្យូមមាន២០ប្រូតុង និង២០ណឺត្រុង

$Z$ លេខអាតូម លេខលំដាប់
ចំនួនប្រូតុង ឬ ចំនួនអេឡិចត្រុង

$$A = N_z + N_{\circ n}$$

$$A = z + {}^{\circ}n$$

**ម៉ាសអាតូម (A)**

ខ.អ មានន័យថាខ្នាតអាតូម $= amu =$ atomic mass unit

ជាបរិមាណអាតូមគិតក្នុង១ខ្នាតអាតូម។ ១ខ្នាតអាតូមគិតស្មើនឹង$\frac{1}{12}$ នៃម៉ាសកាបូន១២
ម៉ាសអាតូមត្រូវបានបង្ហាញដោយ

$A = z + {}^{\circ}n$ ដែល $z$ ជាលេខលំដាប់ឬ ចំនួនប្រូតុង ឬចំនួនអេឡិចត្រុង ${}^{\circ}n$ ជាចំនួនណឺត្រុង



**ម៉ាសម៉ូលេគុល (M)**

តើមានប៉ុន្មានម៉ូលសូដ្យូមក្នុង 0.23g = m =>n = m/M

$$M = \sum_{i=1}^{\infty} A_i$$

**ឧទា.1.៖**

អាស៊ីតផូស្វ័រិចមានរូបមន្ត( $H_3PO_4$ ). គណនាម៉ាសម៉ូលេគុលអាស៊ីតផូស្វ័រិច បើ $A_H = 1amu, A_P = 31amu,$
$A_O = 16$។

$M = 3 \times 1amu + 1 \times 31amu + 4 \times 16amu = 98amu$ (g) or (g/mol= $g.mol^{-1}$) ← ម៉ាសម៉ូល

(g) ← ម៉ាសម៉ូលេគុលក្រាម

**ឧទា.2.៖**

សូដ្យូមកាបូណាតផ្សំពី ២អាតូមសូដ្យូម ១អាតូមកាបូន និង៣អាតូមអុកស៊ីហ្សែន។ គណនា ម៉ាសម៉ូលេគុលរបស់សូដ្យូមកាបូណាត ដោយដឹងថា $A_{Na} = 23amu, A_P = 12amu, \quad A_O = 16amu$ ។

**ម៉ាសម៉ូល ( ខ្នាតគិតជា $g.mol^{-1}$ឬ $Kg.mol^{-1}$ )**

ជាម៉ាសអាតូម ឬ ម៉ាសម៉ូលេគុលគិតជាក្រាម ដែលមានក្នុងមួយម៉ូល។

**ឧទា.3.៖**

អាតូមសូដ្យូមមានម៉ាស 23g ដូច្នេះម៉ាសម៉ូលរបស់អាតូមសូដ្យូមស្មើនឹង $23g.mol^{-1}$។

**ចំនួនអាវ៉ូកាដ្រូ ($N_A$)**

ជាបរិមាណឬចំនួនភាគល្អិតដែលមានក្នុងមួយម៉ូល ដើម្បីឧទ្ទិសដល់អ្នកវិទ្យាសាស្ត្រជនជាតិអ៊ីតាលី ចំនួននេះត្រូវបានហៅថា ចំនួនអាវ៉ូកាដ្រូ ដែលមានតម្លៃស្មើនឹង $6.022 \times 10^{23}$។

**ដូច្នេះ**

$1mol = 6.022 \times 10^{23}$ភាគល្អិត

**ចំនួនម៉ូល (n)**

$$n = \frac{m}{M} = \frac{N}{N_A}$$

**ដែល**

m ជាម៉ាស M ជាម៉ាសម៉ូល N ជាចំនួនភាគល្អិត $N_A$ ជាចំនួនអាវ៉ូកាដ្រូ

**ឧទា.4.៖**

គណនាចំនួនម៉ូលនៃអាតូមស្ពាន់ធ័រដែលមានក្នុង 0.64g។ $A_S = 32amu = 32g \Rightarrow n = \frac{0.64}{32} = 0.02mol$

**ឧទា.5.៖**

គណនាចំនួនអាតូមស្ពាន់ធ័រ ដែលមានក្នុង 1.64g ស្ពាន់ធ័រ។ $A_S = 32amu = 32g \Rightarrow n = \frac{1.64}{32} = 0.05mol$ or $N = 0.05 \times 6.022 \times 10^{23}$



**សមាសភាគសតភាគ (%X)** សំដៅលើភាគរយនៃធាតុផ្សំរបស់វា ឬភាគរយនៃធាតុនីមួយៗដែលមានក្នុងសមាសភាព

$$\%X = \frac{n_X \times M_X \times 100}{M\ of\ compound}$$

$n_x$ជាចំនួនធាតុឬ ចំនួនម៉ូល, $M_x$ ជាម៉ាសអាតូមឬម៉ាសម៉ូលេគុលនៃធាតុ

**ឧទា.6.៖**

គណនាសមាសភាគភាគរយនៃH, Pនិង O ដែលមានក្នុងអាស៊ីដផូស្វ័រិច $H_3PO_4$។ បើម៉ាសម៉ូលរបស់អាស៊ីដផូស្វ័រិច គឺ 98g, $A_H = 1g$ , $A_P = 31g$ និង $A_O = 16g$។ $\%H = \frac{3 \times 1g \times 100}{98g}$ $\%P = \frac{1 \times 31g \times 100}{98g}$ $\%O = \frac{4 \times 16g \times 100}{98g}$

**ឧទា.7.៖**

គណនាសមាសភាគសតភាគនៃធាតុគីមី ដែលមានក្នុងអាស៊ីដអាស្កបិច($C_6H_8O_6$)។ បើ$A_H = 1g$ , $A_C = 12g$ និង $A_O = 16g$។ $\%H = \frac{8 \times 1g \times 100}{(12 \times 6) + (8 \times 1) + (6 \times 16) = 176g}$

**ឧទា.8.៖**

អាលីស៊ីនជាសារធាតុដែលមាននៅក្នុងខ្ទឹម។ គណនារូបមន្តរបស់វា បើតាមការវិភាគគេដឹងថាម៉ូលេគុលរបស់វាមាន

C = 44.4%, H = 6.21%, O = 9.86% & S = 39.5% និងម៉ាសម៉ូលេគុលស្មើនឹង162g។

---

**ចម្លើយ.7.៖**

គណនាម៉ាសម៉ូលេគុល = (6x12amu) + (8x1g) + (6x16g) =176g

គណនា

ម៉ាសម៉ូលេគុល ផលបូកម៉ាសអាតូមទាំងអស់ដែលមានក្នុងម៉ូលេគុល

ម

សមាសភាគសតភាគនៃធាតុគីមី ដែលមានក្នុងអាស៊ីដអាស្កបិច$(C_6H_8O_6)$។ បើ$A_H = 1g$ , $A_C = 12g$ និង $A_O = 16g$។

$n = \frac{m}{M} =$

$5molFe = 5x56g = 280g$

ម៉ាសម៉ូលទឹក ម៉ាសរបស់ទឹកដែលមានក្នុងមួយម៉ូល $= 2x1 + 16 = 18g/mol$

ម៉ាសម៉ូលេគុលទឹក បរិមាណរបស់ទឹកជា ខ.អ ឬ ក្រាម

ម៉ាសម៉ូលេគុលទឹកគិតជាខ.អ$= 2x1amu + 16amu = 18amu$

ម៉ាសម៉ូលេគុលទឹកគិតជាក្រាម $= 2x1g + 16g = 18g$

**ចម្លើយ8.៖**

គណនារូបមន្តរបស់អាលីស៊ីន

តាមរូបមន្ត $\%X = \frac{n_X \times M_X \times 100}{M\ of\ compound} \Longrightarrow n_x = \frac{\%x \times Mof\ compound}{M_x \times 100}$

$\%C = 44.4\% \Longrightarrow n_C = \frac{0.444 \times 162g}{12g} = 5.99 \sim 6$

$\%H = 6.21\% \Longrightarrow n_H = \frac{0.0621 \times 162g}{1g} = 10$

$\%O = 9.86 \Longrightarrow n_C = \frac{0.0986 \times 162g}{16g} = 0.99 \sim 1$

$\%S = 39.5 \Longrightarrow n_C = \frac{0.395 \times 162g}{32g} = 1.99 \sim 2$

=> រូបមន្តរបស់អាលីស៊ីនគឺ $C_6H_{10}OS_2$

**ចម្លើយ 9.៖**

ប៊ីចេងជាសារធាតុបន្ថែមក្នុងម្ហូបអាហារ។ វាបង្កដោយ

$\%C = 35.51, \%H = 4.77, \%N = 8.29, \%O37.85$ & $\% Na = 13.60$ កំណត់រូបមន្តរបស់ប៊ីចេង បើម៉ាសម៉ូលេគុលរបស់វាស្មើនឹង $169g$។

តាមរូបមន្ត $\%X = \frac{n_X \times M_X \times 100}{M\ of\ compound} \Longrightarrow n_x = \frac{\%x \times Mof\ compound}{M_x \times 100}$

$\%C = 35.51\% \Longrightarrow n_C = \frac{0.3551 \times 169g}{12g} = 5$

$\%O = 37.85\% \Longrightarrow n_H = \frac{0.3785 \times 169g}{16g} = 4$

$\%H = 4.77\% \Longrightarrow n_C = \frac{0.0477 \times 169g}{1g} = 8$

$\%N = 8.29 \Longrightarrow n_C = \frac{0.0829 \times 16g}{14g} = 1$

$\%Na = 13.60 \Longrightarrow n_C = \frac{0.1360 \times 169g}{23g} = 1$

=> រូបមន្តរបស់អាលីស៊ីនគឺ $C_5H_8O_4NNa$

## ការកំណត់រូបមន្ត

$$n_X = \frac{\%X}{M_X} \quad \text{or} \quad n_X = \frac{\%X \times M_{compound}}{M_X}$$

**ឧទា.9.៖**

ប៊ីចេងជាសារធាតុបន្ថែមក្នុងម្ហូបអាហារ។ វាបង្កដោយ $\%C = 35.51, \%H = 4.77, \%N = 8.29, \%O = 37.85$ & $\%Na = 13.60$ កំណត់រូបមន្តរបស់ប៊ីចេង បើម៉ាសម៉ូលេគុលរបស់វាស្មើនឹង$169g$។

**ឧទា.10.៖**

ក្លរ៉ូហ្វមត្រូវបានប្រើជាថ្នាំសន្លប់ វាជាសារធាតុពុលដែលធ្វើឲ្យប៉ះពាល់ដល់ថ្លើម។ គណនាសមាសភាគសតភាគរបស់វា។

**ឧទា.11.៖**

សំណរប៉ាហាំងឌីអុកស៊ីតជាធាតុដែលមាននៅក្នុងសំបកផែនដី។ គណនាមាសភាគសតភាគជាម៉ាសរបស់សំណរប៉ាហាំងនិងអុកស៊ីហ្សែនដែលមាននៅក្នុងសំណរប៉ាហាំងឌីអុកស៊ីត។



**ចម្លើយ.9.៖**

តាមរូបមន្ត $n_X = \frac{\%X \times M_{compound}}{M_X \times 100}$

គណនាចំនួនអាតូមរបស់កាបូន

$n_C = \frac{0.3551 \times 169g}{12} = 5$

$n_H = \frac{0.0477 \times 169g}{1} = 8$

$n_O = \frac{0.3785 \times 169g}{16} = 4$

$n_{Na} = \frac{0.1360 \times 169g}{23} = 1$

$n_N = \frac{0.829 \times 169g}{14} = 1$

$\Rightarrow C_5H_8O_4NNa = NaC_5H_8O_4N = MSG$

IUPAC cation 1st anion 2nd Ex: sodium chloride NaCl, sodium acetate $NaCH_3COO$

Organic Radical 1st cation 2nd Ex: sodium acetate $CH_3COONa$

$OH_2 + H_2O \rightleftharpoons H_3O^+ + OH^-$

$OH_2, NH_3 = H_3N, NaCl, CaCO_3$

$CO_3Ca$, $CH_3COOH$, NaCL, $CaCo_3$ aN

ចំពោះអុកស៊ីអាស៊ីដ បច្ច័មបទ ដោយ អ៊ី(ous)ឬ អិច(ic)

Ex: $H_2SO_3$ = Sulfurous acid =អាស៊ីដស៊ុលហ្វួរី $\Rightarrow$ ite

$H_2SO_4$ = Sulfuric acid = អាស៊ីដស៊ុលហ្វួរិច $\Rightarrow$ ate

ចំពោះអ៊ីដ្រូអាស៊ីដ បច្ច័មបទ ដោយ អិច(ic)

Ex: HCl = chloride acid =អាស៊ីដក្លរីឌ្រិច $\Rightarrow$ ide

អុកស៊ីអាស៊ីដ = អុកសូអាស៊ីដ = Oxo-acid

អុកស៊ីតអាស៊ីដ

---

**ឧទា.8.៖**

**អាលីស៊ីនជាសារធាតុដែលមាននៅក្នុងខ្ទឹម។ គណនារូបមន្តរបស់វា បើតាមការវិភាគគេដឹងថាម៉ូលេគុលរបស់វាមាន $C = 44.4\%$, $H = 6.21\%, O = 9.86\%$ & $S = 39.5\%$ និងម៉ាសម៉ូលេគុលស្មើនឹង162g។**

**ចម្លើយ៖**

តាមរូបមន្ត $n_X = \frac{\%X \times M_{compound}}{M_X \times 100} \Rightarrow \%X = \frac{nXMX100}{M}$

គណនាចំនួនអាតូមរបស់កាបូន

$$n_C = \frac{0.444 \times 162g}{12} = 6$$

$$n_H = \frac{0.0621 \times 162g}{1} = 10$$

$$n_O = \frac{0.0986 \times 162g}{16} = 1$$

$$n_S = \frac{0.395 \times 162g}{32} = 2$$

$\Longrightarrow C_6H_{10}OS_2$

គណនាភាគរយអាហ្សូតដែលមាននៅក្នុងអ៊ុយរ៉េ បើអ៊ុយរ៉េមានរូបមន្ត $CO(NH_2)_2$ $N = 46$

| Name | Acid Color | pH Range of Color Change | Base Color |
|---|---|---|---|
| Methyl violet | Yellow | 0.0 - 1.6 | Blue |
| Thymol blue | Red | 1.2 - 2.8 | Yellow |
| Methyl orange | Red | 3.2 - 4.4 | Yellow |
| Bromocresol green | Yellow | 3.8 - 5.4 | Blue |
| Methyl red | Red | 4.8 - 6.0 | Yellow |
| Litmus | Red | 5.0 - 8.0 | Blue |
| Bromothymol blue | Yellow | 6.0 - 7.6 | Blue |
| Thymol blue | Yellow | 8.0 - 9.6 | Blue |
| Phenolphthalein | Colorless | 8.2 - 10.0 | Pink |
| Thymolphthalein | Colorless | 9.4 - 10.6 | Blue |
| Alizarin yellow R | Yellow | 10.1 - 12.0 | Red |






1. ដែកមានប្រតិកម្មជាមួយអុកស៊ីហ្សែនឲ្យផលជា ដែកអុកស៊ីតម៉ាញេទិច $H_2SO_4(l), H_2O(l)(g)$

$3Fe(s) + 2O_2(g) \longrightarrow Fe_3O_4(bronw) = FeO, Fe_2O_3$ អុកស៊ីហ្សែនលើស $H_2SO_4(l) + H_2O \longrightarrow H_3O^+ + SO_4^{2-} + NaCl$

$4Fe(s) + 3O_2(g) \longrightarrow 2Fe_2O_3(red\ bronw)$ ក្នុងបរិយាកាស $O_2(g) + H_2O$

$2Fe(s) + O_2(g) \longrightarrow 2FeO(black)$ ចំហេះមិនសព្វ

2. សូដ្យូមក្លរមានប្រតិកម្មជាមួយអាស៊ីដស៊ុលហ្វួរិចឲ្យផលជាសូដ្យូមស៊ុលហ្វាតនិងអ៊ីដ្រូហ្សែនក្លរ

$2NaCl(aq) + H_2SO_4(l) \longrightarrow Na_2SO_4(aq) + 2HCl(g) = 2Na^+ + 2Cl^- + 2H^+ + SO_4^{2-} \longrightarrow 2Na^+ + SO_4^{2-} + HCl(g)$

$2Cl^- + 2H^+ \longrightarrow HCl(g)$

$Na_2SO_4(aq) + 2HCl(l) \longrightarrow 2NaCl(aq) + H_2SO_4(l) = 2Na^+ + SO_4^{2-} + 2H^+ + 2Cl^- \longrightarrow 2Na^+ + 2Cl^- + 2H^+ + SO_4^{2-}$

## ប្រតិកម្មគីមីនិងសមីការតាងប្រតិកម្មគីមី (Chemical reaction and equation of chemical reaction)

| | |
|---|---|
| 1 | Mono |
| 2 | Di |
| 3 | Tri |
| 4 | Tetra |
| 5 | penta |
| 6 | Hexa |
| 7 | Hepta |
| 8 | Octa |
| 9 | Nona |
| 10 | Deca |
| 11 | Undeca |
| 12 | Dodeca |

**ប្រតិកម្មគីមី = ប្រតិ( ការតបត ) + កម្ម( អំពើ )**

ជាដំណើរការដែលអង្គធាតុមួយឬច្រើន ត្រូវបានផ្លាស់ប្តូរជាអង្គធាតុមួយឬច្រើនថ្មីផ្សេងទៀត។

**សមីការតាងប្រតិកម្មគីមី**

ជាសញ្ញាគីមី ប្រើដើម្បីបង្ហាញពីអ្វី ដែលកើតឡើងក្នុងកំឡុងពេលប្រតិកម្មគីមីប្រព្រឹត្តឡើង។

**ឧទា.12.៖**

ប្រតិកម្មនៃសំណរប៉ាហាំងជាមួយឧស្ម័នក្លរ គេទទួលបានសំណរប៉ាហាំងឌីក្លរ

សមីការតាងប្រតិកម្មគីមី៖

$Sn(s) + Cl_2(g) \rightarrow SnCl_2(s)$

$$2Na(s) + 2H_2O \rightarrow 2NaOH(aq) + H_2(g)$$

$$NaCl(s) \xrightarrow{H_2O} Na^+(aq) + Cl^-(aq)$$

ក្នុងសមីការតាងនេះ សញ្ញា (+) មានន័យថាមានប្រតិកម្មជាមួយ សញ្ញា (→)មានន័យថាទទួលបានឬឲ្យផលជា ក្នុងសមីការតាងប្រតិកម្មគីមីធាតុគីមីដែលនៅខាងឆ្វេង( ក្រោយ )សញ្ញា (→) ហៅថាអង្គធាតុប្រតិករ ចំណែកធាតុគីមីដែលនៅខាងស្តាំ( មុខ )សញ្ញា (→) ហៅថាផលិតផលឬអង្គធាតុកកើត។

**ច្បាប់រក្សារូបធាតុ:** មុននិងក្រោយប្រតិកម្ម គ្មានអាតូមនៃធាតុគីមីណាមួយត្រូវបានបាត់បង់នុះទេ។

**ច្បាប់រក្សាម៉ាស់:** ផលបូកម៉ាសនៃអង្គធាតុប្រតិករ ស្មើនឹងផលបូកម៉ាសនៃអង្គធាតុកកើត។

**ការថ្លឹងសមីការ៖**

១. ការថ្លឹងសមីការងាយ( ប្រើភ្នែកមើល )
២. ការថ្លឹងសមីការតាមពីជគណិត
៣. ការថ្លឹងសមីការតាមអុកស៊ីដូរេដុកម្ម( បណ្តូរអេឡិចត្រុង )
៤. ការថ្លឹងសមីការតាមអុកស៊ីដូរេដុកម្ម( បណ្តូរអេឡិចត្រុង )ក្នុងមជ្ឈដ្ឋានអាស៊ីដឬបាស

**វិធីថ្លឹងសមីការតាមពីជគណិត**

**ដំណាក់កាលទី១:** តាងអញ្ញាត a, b, c,…… ជាមេគុណលំនឹង

**ឧទា.13៖**

$$a FeSO_4(aq) + b KMnO_4(aq) + c H_2SO_4(l) \rightarrow d Fe_2(SO_4)_3(aq) + e K_2SO_4(aq) + f MnSO_4(aq) + g H_2O(g)$$

**ដំណាក់កាលទី2:** ផ្ទឹមធាតុ

**ឧទា. 14៖**

Fe: $a = 2d$ (1)

S: $a + c = 3d + e + f$ (2)

$K: b = 2e$
Mn: $b = f$
$\Rightarrow b = f = 2e$ (3)

O: $4a + 4b + 4c = 12d + 4e + 4f + g$ (4)

H: $2c = 2g \Rightarrow c = g$ (5)

ដំណាក់កាលទី3: ដំណោះស្រាយ

ឧទា.15៖

ជំនួស (1) និង (3) ក្នុងសមីការ (2) យើងបាន៖

$a + c = 3d + e + f$ គឺ $c = d + 3e$ (6)

ជំនួស (1) (3) និង (5) ក្នុងសមីការ (4) នាំឲ្យ៖

$4a + 4b + c = 12d + 4e + 4f + g$ ទៅជា $8d + 8e + 4c = 12d + 4e + 8e + g \Rightarrow 3g = 4d + 4e$ (7)

ជំនួស (6) ក្នុងសមីការ (7)

$3g = 4d + 4e$ ទៅជា $3d + 9e = 4d + 4e \Rightarrow d = 5e$

ដំណាក់កាលទី4: ឲ្យតម្លៃលើអញ្ញាតងាយ

ឧទា.16៖

ឲ្យ $e = 1 \Rightarrow d = 5, a = 10, b = f = 2$ ចំណែក $c = g = d + 3e = 8$

ដំណាក់កាលទី5: ជំនួសក្នុងសមីការដើម

$10FeSO_4(aq) + 2KMnO_4(aq) + 8H_2SO_4(l) \rightarrow 5Fe_2(SO_4)_3(aq) + K_2SO_4(aq) + 2MnSO_2(aq) + 8H_2O(g)$

$10FeSO_4(aq) + 2\ KMnO_4(aq) + 8\ H_2SO_4(l) \rightarrow 5\ Fe_2(SO_4)_3(aq) + K_2SO_4(aq) + 2\ MnSO_4(aq) + 8\ H_2O(g)$

ថ្លឹងតាមពីជគណិត

1. តាងមេគុណលំនឹង
2. ផ្ទឹមធាតុ

Fe: a = 2d (1)

S: a + c = 3d + e + f (2)

O: 4a + 4b + 4c = 12d + 4e +4f +g (3)

K: b = 2e

Mn: b = f => b = f = 2e (4)

H: 2c =2g => c = g (5)

3. ដោះស្រាយ

យក(១)និង(៤)ជំនួសក្នុង(២)

2d+ c = 3d + e + 2e => c = d + 3e (6)

យក(១) (៤) និង(៥)ជំនួសក្នុង(៣)

8d + 8e + 4c = 12d + 4e +8e+c => 3c = 4d + 4e (7)

យក(៦)ជំនួសក្នុង(៧)

3c = 4d + 4e =>3(d+3e) = 4d +4e =>5e = d

4. ឲ្យ e = 1 => d = 5, a = 2d = 10, b = f = 2e = 2,

   c = g = d + 3e = 8

អង្គខាងស្តាំ $5 \times 12 + 4 + 8 + 8 = 80$

អង្គខាងឆ្វេង $40 + 8 + 32 = 80$

**វិធីថ្លឹងសមីការតាមអុកស៊ីដូរេដុកម្ម(បណ្ដូរអេឡិចត្រុង)ក្នុងមជ្ឈដ្ឋានអាស៊ីដឬបាស**

**ជំហានទី1៖ បង្កើតកន្លះសមីការ**

**ឧទា.18៖** $FeSO_4(aq) + K_2Cr_2O_7(aq) + H_2SO_4(aq) \longrightarrow Fe_2(SO_4)_3(aq) + K_2SO_4(aq) + Cr_2(SO_4)_3(aq) + H_2O(l)$

**បង្កើតកន្លះសមីការ**

$OX: \quad 2Fe^{2+} \longrightarrow 2Fe^{3+} + 2e^-$

$RED: \quad Cr_2O_7^{2-} + e^- \longrightarrow 2Cr^{3+}$

**ថ្លឹងក្នុងមជ្ឈដ្ឋានអាស៊ីដ គឺត្រូវបូក** $H^+$ **នៅអង្គទី១ បន្ថែមទឹកនៅអង្គទី២ឲ្យគ្រប់នឹងចំនួនអុកស៊ីហ្សែននៅអង្គទី១**

**ថ្លឹងក្នុងមជ្ឈដ្ឋានបាស គឺត្រូវបូកទឹកនៅអង្គទី១ឲ្យគ្រប់នឹងចំនួនអុកស៊ីហ្សែន បន្ថែម** $OH^-$ **នៅអង្គទី២**

**ឧទា.19៖** **ថ្លឹងក្នុងមជ្ឈដ្ឋានអាស៊ីដ**

$OX: \quad 2Fe^{2+} \longrightarrow 2Fe^{3+} + 2e^-$

$RED: \quad Cr_2O_7^{2-} + 14H^+ + 6e^- \longrightarrow 2Cr^{3+} + 7H_2O$ (១)

**ថ្លឹងក្នុងមជ្ឈដ្ឋានបាស**

$OX: \quad 2Fe^{2+} \longrightarrow 2Fe^{3+} + 2e^-$

$RED: \quad Cr_2O_7^{2-} + 7H_2O + 6e^- \longrightarrow 2Cr^{3+} + 14OH^-$ (២)

**តែដោយសមីការរបស់យើងឋិតនៅក្នុងមជ្ឈដ្ឋានអាស៊ីដ យើងថ្លឹងតាម(១)**

ចំនួនអុកស៊ីតកម្ម គេសរសេរសញ្ញានៅមុខលេខ ឧទា.៖ sodium មានចំនួនអុកស៊ីតកម្ម +1, អាលុយមីញ៉ូមមានចំនួនអុកស៊ីតកម្ម +3 អាហ្សូត មានវ៉ាឡង់តែមួយគត់គឺ(III) តែវាមានចំនួនអុកស៊ីតកម្ម -3($NH_3$), 0($N_2$), +1 ($N_2O$), +2 (NO), +3 ($N_2O_3$), +4($N_2O_4$) and +5 ($N_2O_5$) ព្រោះវាមាន៣អេឡិចត្រុងសេរី

បន្ទុកគេសរសេរលេខនៅមុខសញ្ញា sodium មានបន្ទុក 1+ អាលុយមីញ៉ូមមានបន្ទុក 3 +

វ៉ាឡង់ គេសរសេរលេខរ៉ូម៉ាំងដាក់ក្នុងវង់ក្រចក sodium មានវ៉ាឡង់ (I)

ច្បាប់នៃចំនួនអុកស៊ីតកម្ម

១. គ្រប់អាតូម និងម៉ូលេគុលមានចំនួនអុកស៊ីតកម្មស្មើ0. EX Na, Fe, HCl, $KMnO_4$, $K_2SO_4$

២. បន្សំនៃធាតុគីមី: ធាតុដែលមានកម្រិតអេឡិចត្រូអវិជ្ជមានធំ ជាអ៊ីយ៉ុងអវិជ្ជមាន ធាតុដែលមានកម្រិតអេឡិចត្រូអវិជ្ជមានតូច ជាអ៊ីយ៉ុងវិជ្ជមាន EX: NO $\chi_N = 3.04 < \chi_O = 3.5 \Longrightarrow$ N ជាអ៊ីយ៉ុងវិជ្ជមាន

៣. អាតូមម៉ូណូវ៉ាឡង់ ចំនួនអុកស៊ីតកម្ម ស្មើនឹងវ៉ាឡង់ EX: Na មានវ៉ាឡង់មួយ ចំនួនអុកស៊ីតកម្មស្មើ +1 អាលុយមីញ៉ូមមានវ៉ាឡង់បី ចំនួនអុកស៊ីតកម្ម +3

៤. អ៊ីដ្រូហ្សែនមានចំនួនអុកស៊ីតកម្ម +1 ជានិច្ច លើកលែងតែពេលវាផ្សំជាមួយធាតុដែលមានកម្រិតអេឡិចត្រុងអវិជ្ជមានតូចជាងវា

ឧទា.៖ HCl, $NH_3$, $H_2S$are n.o = +1     NaH, $MgH_2$, LiH are n.o = −1

៥. អុកស៊ីហ្សែនមានចំនួនអុកស៊ីតកម្ម -2 ជានិច្ច លើកលែងតែក្នុងពែរអុកស៊ីត (-1) ស៊ុបពែរអុកស៊ីត(-1/2)និងអុកស៊ីហ្សែនីល(+2)

ឧទា.$Li_2O$, $H_2O$, MgO, NO, $CO_2$, $SO_3$   ពែរអុកស៊ីត $Na_2O_2$, $H_2O_2$, $BaO_2$,   ស៊ុបពែរអុកស៊ីត $KO_2$, $RbO_2$, $CsO_2$   អុកស៊ីហ្សែនីល $OF_2$

$\overset{+2}{6FeSO_4}(aq) + K_2\overset{+6}{Cr_2}O_7(aq) + 7H_2SO_4(aq) \longrightarrow 3\overset{+3}{Fe_2}(SO_4)_3(aq) + K_2SO_4(aq) + \overset{+3}{Cr_2}(SO_4)_3(aq) + 7H_2O(l)$

Step 2 បង្កើតកន្លះសមីការតុល្យការ

តើអុកស៊ីតកម្ម? ចំនួនអុកស៊ីតកម្មកើន

តើរេដុកម្ម? ចំនួនអុកស៊ីតកម្មថយ

OX: $red \to ox + e^- = no \uparrow$, RED: $ox + e^- \to red = no \downarrow$

មជ្ឈដ្ឋានបាស

OX $2Fe^{2+} \to 2Fe^{3+} + 2e^-$

RED $Cr_2O_7^{2-} + 7H_2O + 6e^- \to 2Cr^{3+} + 14OH^-$

មជ្ឈដ្ឋានអាស៊ីដ

OX $2Fe^{2+} \to 2Fe^{3+} + 1e^-$

RED $Cr_2O_7^{2-} + 14H^+ + 6e^- \to 2Cr^{3+} + 7H_2O$

Charge $(2-) + (14+) \to (6+)$

$(12+) + 6e^- \to (6+)$

Step 3 បង្កើតសមីការតុល្យការ

គុណចម្រាសចំនួនអេឡិចត្រុងប្តូរ

OX $2Fe^{2+} \to 2Fe^{3+} + 2e^-$ $\times 6e^-$

RED $Cr_2O_7^{2-} + 14H^+ + 6e^- \to 2Cr^{3+} + 7H_2O$ $\times 2e^-$

បូកអង្គនឹងអង្គ

$6Fe^{2+} + Cr_2O_7^{2-} + 14H^+ + 6e^- = 6Fe^{3+} + 2Cr^{3+} + 7H_2O + 6e^-$

សម្រួលអេឡិចត្រុង

$6Fe^{2+} + Cr_2O_7^{2-} + 14H^+ = 6Fe^{3+} + 2Cr^{3+} + 7H_2O$

Step 4 ជំនួសក្នុងសមីការដើម

Step 5 ផ្ទៀងផ្ទាត់

$24 + 7 + 28 = 36 + 4 + 12 + 7$

$59 = 59$

**ជំហានទី2៖ បង្កើតសមីការតុល្យការ**

ក្នុងការបង្កើតសមីការតុល្យការត្រូវ៖

គុណចម្រាសចំនួនអេឡិចត្រុងដែលប្តូរ

បូកកន្លះសមីការទាំងពីរបញ្ចូលគ្នា ( បូកអង្គនឹងអង្គ )

សម្រួលអេឡិចត្រុងចេញ

**ឧទ.20៖** $OX$: $2Fe^{2+} \longrightarrow 2Fe^{3+} + 2e^- \times 3e^-$

$RED$: $Cr_2O_7^{2-} + 14H^+ + 6e^- \longrightarrow 2Cr^{3+} + 7H_2O \times 1e^-$

REDOX: $6Fe^{2+} + Cr_2O_7^{2-} + 14H^+ + 6e^- \longrightarrow 6Fe^{3+} + 2Cr^{3+} + 7H_2O + 6e^-$

$6Fe^{2+} + Cr_2O_7^{2-} + 14H^+ \longrightarrow 6Fe^{3+} + 2Cr^{3+} + 7H_2O$

**ជំហានទី3៖ ជំនួសក្នុងសមីការដើម**

$6FeSO_4(aq) + K_2Cr_2O_7(aq) + 7H_2SO_4(aq) \longrightarrow 3Fe_2(SO_4)_3(aq) + K_2SO_4(aq) + Cr_2(SO_4)_3(aq) + 7H_2O(l)$

**ជំហានទី4៖ ផ្ទៀតផ្ទាត់**

ចំនួនអុកស៊ីហ្សែននៅអង្គទី១គឺ $24 + 7 + 28 = 59$ = ចំនួនអុកស៊ីហ្សែននៅអង្គទី២គឺ$(3 \times 4 \times 3) + 4 + 12 + 7 = 59$

---

**ស្តីស្យូមេទ្រី :**

ជាការកំណត់បរិមាណនៃអង្គធាតុប្រតិករឬផលិតផលដោយប្រើវិធីម៉ូល

**ជំហានទី1៖** សរសេរសមីការតាងប្រតិកម្មឲ្យបានត្រឹមត្រូវ

**ជំហានទី2៖** គណនាចំនួនម៉ូលដែលគេឲ្យ

**ជំហានទី3៖** គណនាចំនួនម៉ូលនៃធាតុគីមីដែលមិនស្គាល់ តាមរយៈមេគុណលំនឹង(វិចារតាមវិធានត្រីយ៉ាន)

**ជំហានទី4៖** ប្រើចំនួនម៉ូលដែលគណនាបាន ប្តូរជាបរិមាណនៃធាតុដែលមិនស្គាល់(គិតជាក្រាម)

**ជំហានទី5៖** ផ្ទៀងផ្ទាត់

**ឧទា.21៖**

អ៊ុយរេត្រូវបានផលិតតាមសមីការខាងក្រោម៖

$$NH_3(g) + CO_2(g) \xrightarrow{\Delta} CO(NH_2)_2(s) + H_2O(g)$$

ក្នុងប្រតិកម្មនេះ គេប្រើអាម៉ូញ៉ាក់ 637.2g មានប្រតិកម្មជាមួយឧស្ម័នកាបូនិច 1142g។

ក.ធាតុគីមីណាមួយជាប្រតិករកំណត់

ខ. គណនាម៉ាសអ៊ុយរេដែលទទួលបាន

ឃ. គណនាបរិមាណធាតុគីមីដែលនៅសល់

**ចម្លើយ:**

**ជំហានទី1៖** សរសេរសមីការតាងប្រតិកម្ម

$$2NH_3(g) + CO_2(g) \xrightarrow{\Delta} CO(NH_2)_2(s) + H_2O(g)$$

**ជំហានទី2៖** គណនាចំនួនម៉ូលដែលគេឲ្យ

$$n_{NH_3} = \frac{m_{NH_3}}{M_{NH_3}} = \frac{637.2g}{17g.mol^{-1}} = 37.5mol \pm 0.02$$

$$n_{CO_2} = \frac{m_{CO_2}}{M_{CO_2}} = \frac{1142g}{44g.mol^{-1}} = 26mol \pm 0.04$$

**ជំហានទី3៖** តាមសមីការតាងប្រតិកម្ម

2mol អាម៉ូញ៉ាក់ចូលរួមប្រតិកម្មជាមួយឧស្ម័នកាបូនិច 1mol ឲ្យអ៊ុយរេ 1mol និងទឹក 1mol

**ដូចនេះ:**

$37.5mol$ អាម៉ូញ៉ាក់ចូលរួមប្រតិកម្មជាមួយឧស្ម័នកាបូនិច $\frac{37,5mol}{2}$ ឲ្យអ៊ុយរេ $\frac{37,5mol}{2}$

$\Rightarrow$ ចំនួនម៉ូលឧស្ម័នកាបូនិចសល់គឺ $26.00\text{mol} - 18.75\text{mol} = 7.25\text{mol}$

ដូច្នេះ

អាម៉ូញ៉ាក់ជាប្រតិករកំណត់

បរិមាណអ៊ុយរេកើតគឺ : $\frac{37.50}{2}\text{mol} \times 60\text{g.mol}^{-1} = 1125.00\text{g}$

បរិមាណធាតុតីមីដែលនីសល់: $7.25\text{mol} \times 44\text{g.mol}^{-1} = 319.00\text{g}$

ឧទា.22៖

ប្រតិកម្មរវាងអាលុយមីញ៉ូមជាមួយដែក( )អុកស៊ីតជាប្រតិកម្មបញ្ចេញកម្តៅ តាមលំនាំសមីការខាងក្រោម

$2\text{Al(s)} + \text{Fe}_2\text{O}_3\text{(s)} \rightarrow 2\text{Fe} + \text{Al}_2\text{O}_3$

ក.តើគណនាបរិមាណ$\text{Al}_2\text{O}_3$ទទួលបាន បើគេប្រើអាលុយមីញ៉ូម124g ឲ្យមានប្រតិកម្មជាមួយដែក(III)អុកស៊ីត601g។

ខ. តើប្រតិករលើសនៅសល់ប៉ុន្មាន ក្រោយប្រតិកម្មចប់

ប្រតិកម្មរវាងអាលុយមីញ៉ូមជាមួយដែក( )អុកស៊ីតជាប្រតិកម្មបញ្ចេញកម្តៅ តាមលំនាំសមីការខាងក្រោម

$2\text{Al(s)} + \text{Fe}_2\text{O}_3\text{(s)} \rightarrow 2\text{Fe} + \text{Al}_2\text{O}_3$

ក.តើគណនាបរិមាណ$\text{Al}_2\text{O}_3$ទទួលបាន បើគេប្រើអាលុយមីញ៉ូម124g ឲ្យមានប្រតិកម្មជាមួយដែក(III)អុកស៊ីត601g។

ខ. តើប្រតិករលើសនៅសល់ប៉ុន្មាន ក្រោយប្រតិកម្មចប់

ចម្លើយ៖

សមីការតាងប្រតិកម្មគឺមី

$2\text{Al(s)} + \text{Fe}_2\text{O}_3\text{(s)} \rightarrow 2\text{Fe} + \text{Al}_2\text{O}_3$

គណនាចំនួនម៉ូល

$n_{\text{Al}} = \frac{124\text{g}}{27\text{g/mol}} = 4.59\text{ mol}$

$n_{\text{Fe}_2\text{O}_3} = \frac{601\text{g}}{160\text{g/mol}} = 3.75\text{mol}$

តាមសមីការតាងប្រតិកម្មគឺមី

2mol Al ត្រូវការ 1mol $\text{Fe}_2\text{O}_3$ 2mol ដែក

4.59 mol Al ត្រូវការ $\frac{4.59\text{ mol}}{2}$ $\text{Fe}_2\text{O}_3$ ឲ្យ 4.59 mol ដែក $+ \frac{4.59\text{ mol}}{2}$ $\text{Al}_2\text{O}_3$

$\Rightarrow$ចំនួនម៉ូលរបស់ $\text{Fe}_2\text{O}_3$ សល់គឺ $3.75\text{mol} - \frac{4.59\text{ mol}}{2} = 1.46\text{mol}$

បរិមាណរបស់ $\text{Al}_2\text{O}_3$ ទទួលបានគឺ$2.3mol \times 102g/mol = 234.6g$

បរិមាណរបស់ $\text{Fe}_2\text{O}_3$ សល់គឺ$1.46mol \times \frac{160g}{mol} = 233.6g$

$$n_{Fe} = \frac{280}{56} mol = 5mol$$

$$n_{O_2} = \frac{192}{32} mol = 6mol$$

**តាមសមីការតាងប្រតិកម្មគីមី**

$3Fe \quad + 2O_2 \quad \rightarrow Fe_3O_4$

$3mol \quad + 2mol \quad \rightarrow 1mol Fe_3O_4$

$5mol \quad + x\ mol \quad \rightarrow 5/3 mol Fe_3O_4$

$$\Longrightarrow x = \frac{5 \times 2}{3}$$

**ដូច្នេះ ចំនួនម៉ូលអុកស៊ីហ្សែនដែលចូលរួមប្រតិកម្ម** ( 10/3 ) **តិចជាងចំនួនម៉ូលរបស់អុកស៊ីហ្សែនដែលឲ្យ** ( $6mol$ )**។**

$\Longrightarrow$ Fe **ជាប្រតិករកំណត់**

**ចំនួនអុកស៊ីហ្សែនដែលសល់គឺ** $6mol - \frac{10}{3} mol = 2.7mol$

$$m_{Fe_3O_4} = \frac{5}{3mol} \times 232g.mol^{-1} = 386.66g$$

$$m_{O_2 \text{សល់}} = 2.7mol \times 32g.mol^{-1} = 86.4g$$

**ប្រធានលំហាត់៖**

**ក. គណនាបរិមាណដែកម៉ាញេទិចដែលទទួលបានពីប្រតិកម្មរវាង** $280g$ **ដែកជាមួយ** $192g$ **អុកស៊ីហ្សែន**

**ខ. គណនាបរមាណធាតុដែលនៅសល់ក្រោមប្រតិកម្ម។**

**មេរៀនទី២**

# ទម្រង់អាតូម និង តារាងខួបនៃធាតុគីមី

## Atomic structure and Periodic table of elements

## គោលការណ៍លើកលែងរបស់ Pauli :

### 1. ចំនួនកង់ទិច:

**ចំនួនកង់ទិចមេ( n ):** បង្ហាញពីថាមពលអេឡិចត្រុងក្នុងស្រទាប់នីមួយៗ ឬវាតំណាងឲ្យស្រទាប់អេឡិចត្រុង ជាមួយ៖

| $n \in \mathbb{N}^*$ (ជាចំនួនគត់ធម្មជាតិ) | 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|---|
| សន្មតឈ្មោះស្រទាប់អេឡិចត្រុង | K | L | M | N | O | P | Q |

**ចំនួនកង់ទិចអ័របីតាល់( l ):** បង្ហាញពីរូចសណ្ឋានអេឡិចត្រុងក្នុងស្រទាប់រងនីមួយៗ ឬវាតំណាងឲ្យស្រទាប់រងអេឡិចត្រុង

| $l \in \mathbb{N}$ (ជាចំនួនគត់) | 0 | 1 | 2 | 3 | 4 |
|---|---|---|---|---|---|
| សន្មតឈ្មោះស្រទាប់រងអេឡិចត្រុង | s | p | d | f | g |

ចំពោះមួយតម្លៃនៃ n នំុះ l មាន n តម្លៃ

**ឧទា.1៖**

ពេល $n = 1 \Rightarrow l$ មាន 1 តម្លៃ គឺ $l = 0$ ជាអ័របីតាល់ 1s

ពេល $n = 2 \Rightarrow l$ មាន 2 តម្លៃ គឺ $l = 0, 1$ ជាអ័របីតាល់ 2s, 2p

ពេល $n = 3 \Rightarrow l$ មាន 3 តម្លៃ គឺ $l = 0, 1, 2$ ជាអ័របីតាល់ 3s, 3p, 3d

$2n^2$ ជារូបមន្តស្រទាប់ឆ្អែតអេឡិចត្រុង

ស្រទាប់ K (n = 1) អាចមាន២អេឡិចត្រុងអតិបរិមា

ស្រទាប់ M (n = 3) អាចមាន១៨អេឡិចត្រុងអតិបរិមា

ស្រទាប់ O (n = 5) អាចមាន ៥០ អេឡិចត្រុងអតិបរិមា

**ឧទា.1៖**

ពេល $n = 2$ (L) $\Rightarrow l$ មាន២តម្លៃ គឺ $l = 0(s), 1(p)$

$\Rightarrow$ L : 2s. 2p




អ័របីតាល់អាតូម គឺ គន្លងដែលអេឡិចត្រុងចរក្នុងលំហរ ចិតសម្រាប់ដាក់អេឡិចត្រុង

ពេល $n = 1$, $l = 0 \Rightarrow m_l$ មាន $2 \times 0 + 1$តម្លៃ គឺ $m_l = 1$

មានន័យថាមាន1 អ័របីតាល់

តើ 1 អ័របីតាល់បិតក្នុងទម្រង់បែប



ពេល $n = 3$, $l = 0 \Rightarrow m_l$ មាន $2 \times 0 + 1$តម្លៃ (មាន1 អ័របីតាល់)




$l = 1 \Rightarrow m_l$ មាន $2 \times 1 + 1$តម្លៃ (មាន3 អ័របីតាល់)




$l = 2 \Rightarrow m_l$ មាន $2 \times 2 + 1$តម្លៃ (មាន5 អ័របីតាល់)



ពេល $n = 4$, $l = 0 \Rightarrow m_l$ មាន $2 \times 0 + 1$តម្លៃ (មាន1 អ័រប៊ីតាល់)

$l = 1 \Rightarrow m_l$ មាន $2 \times 1 + 1$តម្លៃ (មាន3 អ័រប៊ីតាល់)

$l = 2 \Rightarrow m_l$ មាន $2 \times 2 + 1$តម្លៃ (មាន5 អ័រប៊ីតាល់)

$l = 3 \Rightarrow m_l$ មាន $2 \times 3 + 1$តម្លៃ (មាន7 អ័រប៊ីតាល់)

$n = 4$ មាន16 អ័រប៊ីតាល់ $\Rightarrow 2 \times 4^2 = 32e^-$

$l = 0 \Rightarrow m_l$ មាន $2 \times 0 + 1$តម្លៃ គឺ $m_l = 0$

$l = 1 \Rightarrow m_l$ មាន $2 \times 1 + 1$តម្លៃ គឺ $m_l = -1, 0, +1$

$l = 3 \Rightarrow m_l$ មាន $2 \times 3 + 1$តម្លៃ គឺ $m_l = -3, -2, -1, 0, +1, +2, +3$

$Na(z = 11)$មាន$11e^- = 1s^2 2s^2 2p^6 3s^1$

$\Rightarrow K(1s^2)$ $L(2s^2 2p^6)$ $M(3s^1 3p^0 3d^0)$






$e_1 : n = 1, l = s = 0, m_l = 0, m_s = +\frac{1}{2}$

$e_1 : n = 1, l = s = 0, m_l = 0, m_s = -\frac{1}{2}$

Diamagnetic ជាអាតូមឬម៉ូលេគុលដែលមានស្ពីនគូ

Paramagnetic ជាអាតូមឬម៉ូលេគុលដែលមានស្ពីនសេស

**ចំនួនកង់ទិចម៉ាញេទិច($m_l$):** បង្ហាញពីលំហរដែលអាចរកឃើញអេឡិចត្រុង ឬជាថតអេឡិចត្រុង។ ១តម្លៃរបស់ $m_l$ តាងឲ្យ ១ អ័រប៊ីតាល់ ដែលតម្លៃនេះស្មើនឹង $2l + 1$ របស់ $l$។ តម្លៃរបស់ គឺ $m_l \in \mathbb{Z}$ យកពី $-l, 0, +l$

**ឧទា.2៖**

ពេល $n = 1$, $l = 0 \Rightarrow m_l$ មាន $2 \times 0 + 1$តម្លៃ គឺ $m_l = 1$ មានន័យថាមាន1 អ័រប៊ីតាល់(AO)

ពេល $n = 2$, $l = 0 \Rightarrow m_l$ មាន $2 \times 0 + 1$តម្លៃ គឺ $m_l = 1$ មានន័យថាមាន1 អ័រប៊ីតាល់

$l = 1 \Rightarrow m_l$ មាន $2 \times 1 + 1$តម្លៃ គឺ $m_l = 3$ មានន័យថាមាន 3 អ័រប៊ីតាល់

ពេល $n = 3$, $l = 0 \Rightarrow m_l$ មាន $2 \times 0 + 1$តម្លៃ គឺ $m_l = 1$ មានន័យថាមាន1 អ័រប៊ីតាល់

$l = 1 \Rightarrow m_l$ មាន $2 \times 1 + 1$តម្លៃ គឺ $m_l = 3$ មានន័យថាមាន 3 អ័រប៊ីតាល់

$l = 2 \Rightarrow m_l$ មាន $2 \times 2 + 1$តម្លៃ គឺ $m_l = 5$ មានន័យថាមាន 5 អ័រប៊ីតាល់

**ចំនួនកង់ទិចស្ពីន($m_s$):** បង្ហាញចលនាស្វ័យរង្វិលនៃអេឡិចត្រុងជុំវិញណ្វៃយ៉ូ។ ជានិច្ចកាលតម្លៃ $m_s$ គឺស្មើនឹង $\pm\frac{1}{2}$

$m_s = +\frac{1}{2}$ ហៅថាស្ពីនស្រប តាងដោយ ↑

$m_s = -\frac{1}{2}$ ហៅថាស្ពីនច្រាស តាងដោយ ↓

## 2. គោលការណ៍លើកលែង Pauli:

**ពំនោល១** " ២អេឡិចត្រុងមិនអាចមានតម្លៃនៃចំនួនកង់ទិចទាំង៤ដូចគ្នាទេ"

**ឧទា.3៖**

អាតូមអេល្យូមមានលេខលំដាប់២ មានន័យថាវាមាន២អេឡិចត្រុង ដែលអេឡិចត្រុងតាងដោយ $e_1$, $e_2$ ក្នុង $1s$

ចំពោះអេឡិចត្រុងទី១ $e_1$ មាន $n=1, l=0, m_l=0, m_s=+\frac{1}{2}$

ចំណែកអេឡិចត្រុងទី២ $e_2$ មាន $n=1, l=0, m_l=0, m_s=-\frac{1}{2}$

**ឧទា.4៖**

អាតូមលីចូម មាន៣អេឡិចត្រុង(ស្រទាប់ទី១មាន២អេឡិចត្រុង, ស្រទាប់ទី២មាន១អេឡិចត្រុង) $e_1, e_2, e_3$

$e_1$មាន $n=1, l=0, m_l=0, m_s=+\frac{1}{2}$

$e_2$ មាន $n=1, l=0, m_l=0, m_s=-\frac{1}{2}$

$e_3$ មាន $n=2, l=0, m_l=0, m_s=+\frac{1}{2}$

**ពំនោល២** " ការបំពេញអេឡិចត្រុងក្នុងអ័រប៊ីតាល់អាតូម ត្រូវបំពេញពីថាមពលទាបទៅខ្ពស់"

គឺ$1s > 2s > 2p > 3s > 3p > 4s > 3d > 4p \ldots\ldots\ldots.$

## គោលការណ៍បំពេញអេឡិចត្រុង

**ពំនោល**"ការបំពេញអេឡិចត្រុងក្នុងអ័រប៊ីតាល់អាតូម ត្រូវបំពេញតាមតម្លៃផលបូក n + l តូចទៅធំ ករណីតម្លៃផលបូកស្មើគ្នា អេឡិចត្រុងបំពេញទៅលើ n ដែលមានតម្លៃតូចមុន"




**ឧទា.5៖**

លីចូម$(z=3)$ $1s^2 2s^1$

សូដ្យូម $(z=11)$ $1s^2 2s^2 2p^6 3s^1$

ក្លរ $(z=17)$ $1s^2 2s^2 2p^6 3s^2 3p^5$

នេអុង $(z=11)$ $1s^2 2s^2 2p^6$

Br $(z=35)$ $[Ar]4s^2 3d^{10} 4p^6$

Hg $(z=80)$ $[Xe]6s^2 4f^{14} 5d^{10}$

Lu $(z=71)[Xe]6s^2 4f^{14} 5d^1$

K $(z=19)$ $1s^2 2s^2 2p^6 3s^2 3p^6 4s^1$

Cu $(z=29)$ $[Ar]4s^2 3d^9$

$= [Ar]4s^1 3d^{10}$

**ឧទា.4៖**

Configuration structure **របាយអេឡិចត្រុង ឬ ទម្រង់អេឡិចត្រុង ឬ រូបសណ្ឋានអេឡិចត្រុង**

$Og(z = 118)1s^2 \mid 2s^2 2p^6 \mid 3s^2 3p^6 \mid 4s^2 3d^{10} 4p^6 \mid 5s^2 4d^{10} 5p^6 \mid 6s^2 4f^{14} 5d^{10} 6p^6 \mid 7s^2 5f^{14} 6d^{10} 7p^6$

$[He]^{2}$

$[Ne]^{10}$

$[Ar]^{18}$

$[Kr]^{36}$

$[Xe]^{54}$

$[Rn]^{86}$

**របាយអេឡិចត្រុងក្នុងស្រទាប់និមួយៗ**

| Og | | | |
|---|---|---|---|
| | Q | = | 8 |
| | P | = | 18 |
| | O | = | 15 |
| | N | = | 32 |
| | M | = | 18 |
| | L | = | 8 |
| | K | = | 2 |

$\Rightarrow$ **ការសរសេររបាយអេឡិចត្រុងដោយប្រើទម្រង់ឧស្ម័នកម្រ**

$Og(z = 118)[Rn]7s^2 5f^{14} 6d^{10} 7p^6$

**ឧទា.5៖**

**ចូរសរសេររបាយអេឡិចត្រុងរបស់ ធាតុគីមីដែលមានលេខលំដាប់៧៥ ដោយប្រើទម្រង់ឧស្ម័នកម្រ។**

$X(z = 75)[Xe]6s^2 4f^{14} 5d^5$

**ឧទា.6៖**

$Rh(z = 45) = 45e^- : 1s^2 \mid 2s^2 2p^6 \mid 3s^2 3p^6 \mid 4s^2 3d^{10} 4p^6 \mid 5s^2 4d^5$

$[He]$

$[Ne]$

$[Ar]$

$[Kr]$

$Rh = [Kr]5s^2 4d^5$

**ឧទា.7៖**

$Hg\ (z = 80) = 80e^- : [Xe]6s^2 4f^{14} 5d^{10}$

$Ge\ (z = 32) = 32e^- : [Ar]4s^2 3d^{10} 4p^2$

$Cr(z = 24) = 24e^- : [Ar]4s^2 3d^4 = [Ar]4s^1 3d^5$ **ស្រទាប់រងពាក់កណ្ដាលឆ្អែត**

$Cu(z = 29) = 29e^- : [Ar]4s^2 3d^9 = [Ar]4s^1 3d^{10}$**ស្រទាប់រងឆ្អែត**

$Pd\ (z = 46) = 48e^- : [Kr]5s^2 4d^8 = [Kr]4d^{10}$

**The Hund's law**

“នៅក្នុងអ័រប៊ីតាល់អាតូមមួយដែលមានថាមពលស្មើគ្នា អេឡិចត្រុងបំពេញទៅលើអ័រប៊ីតាល់ ត្រូវបំពេញស្ពីនស្របជាមុន បន្ទាប់មកស្ពីនច្រាស”

“បំពេញទៅលើអ័រប៊ីតាល់ ត្រូវបំពេញដោយលៃយ៉ាងណាឲ្យតម្លៃផលបូកស្ពីនអតិបរមា”

**ឧទា.៨៖**

| | | | | |
|---|---|---|---|---|
| **អាសូត** (N(z-7)) $1s^2\ 2s^2\ 2p^3$ | | ↑↓ | ↑↓ | ↑ ↑ ↑ |
| **ក្លរ** (Cl(z=17)) $[Ne]\ 3s^2\ 3p^5$ | $[Ne]^{10}$ | | ↑↓ | ↑↓ ↑↓ ↑ |
| **ទង់ដែង** (Cu(z=29)) $[Ar]\ 4s^2\ 3d^9$ | $[Ar]^{18}$ | | ↑↓ | ↑↓ ↑↓ ↑↓ ↑↓ ↑ |
| **ក្រូម** (Cr(z=24)) $[Ar]\ 4s^2\ 3d^4$ | $[Ar]^{18}$ | | ↑↓ | ↑ ↑ ↑ ↑ ☐ |

⟹ អេឡិចត្រុងវ៉ាឡង់ ជាអេឡិចត្រុងស្រទាប់ក្រៅបង្អស់
វ៉ាឡង់ ជាអេឡិចត្រុងសេរីនៅស្រទាប់ក្រៅបង្អស់
សណ្ឋានគ្រឹះ ជាសណ្ឋានដំបូងរបស់អេឡិចត្រុង
សណ្ឋានភ្ញោច ជាសណ្ឋានដែលអេឡិចត្រុងនៅស្រទាប់ក្រៅបង្អស់ ផ្លាស់ទីទៅស្រទាប់មួយផ្សេងទៀត

**ឧទា.9៖**

N(z = 7): $[He]2s^2 2p^3$

Cl(z=17): $[Ne]\ 3s^2 3p^5$

$Cl_2O_3$
$Cl_2O_5$
$Cl_2O_7$

| | | | | |
|---|---|---|---|---|
| **សណ្ឋានគ្រឹះ** | $[Ne]^{10}$ | ↑↓ | ↑↓ ↑↓ ↑ | |
| **សណ្ឋានភ្ញោចទី១** | $[Ne]^{10}$ | ↑↓ | ↑↓ ↑ ↑ | ↑ ☐ ☐ ☐ ☐ |
| **សណ្ឋានភ្ញោចទី២** | $[Ne]^{10}$ | ↑↓ | ↑ ↑ ↑ | ↑ ↑ ☐ ☐ ☐ |
| **សណ្ឋានភ្ញោចទី៣** | $[Ne]^{10}$ | ↑ | ↑ ↑ ↑ | ↑ ↑ ↑ ☐ ☐ |

**ឧទា.10៖**

$Cu(z = 29): [Ar]4s^2 3d^9 \Rightarrow [Ar]4s^1 3d^{10}$ ជាករណីស្រទាប់រងឆ្អែត

$Ag(z = 47): [Kr]5s^2 4d^9 \Rightarrow [Kr]5s^1 4d^{10}$ ជាករណីស្រទាប់រងឆ្អែត

$Cr(z = 24): [Ar]4s^2 3d^4 \Rightarrow [Ar]4s^1 3d^5$ ជាករណីស្រទាប់រងពាក់កណ្ដាលឆ្អែត

$W(z = 73): [Xe]6s^2 4f^{14} 3d^4 \Rightarrow [Xe]6s^1 4f^{14} 3d^5$ ជាករណីស្រទាប់រងពាក់កណ្ដាលឆ្អែត

$Pd(z = 46): [Kr]5s^2 4d^8 \Rightarrow [Kr]4s^0 3d^{10}$ ជាករណីពិសេស

## តារាងខួបនៃធាតុគីមី

ខួប →

ក្រុម ↓

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| H | | | | | | | | | | | | | | | | | He |
| Li | Be | | | | | | | | | | | B | C | N | O | F | Ne |
| Na | Mg | | | | | | | | | | | Al | Si | P | S | Cl | Ar |
| K | Ca | Sc | Ti | V | Cr | Mn | Fe | Co | Ni | Cu | Zn | Ga | Ge | As | Se | Br | Kr |
| Rb | Sr | Y | Zr | Nb | Mo | Tc | Ru | Rh | Pd | Ag | Cd | In | Sn | Sb | Te | I | Xe |
| Cs | Ba | Lu | Hf | Ta | W | Re | Os | Ir | Pt | Au | Hg | Tl | Pb | Bi | Po | At | Rn |
| Fr | Ra | Lr | Rf | Db | Sg | Bh | Hs | Mt | Ds | Rg | Cn | Nh | Fl | Mc | Lv | Ts | Og |
| Uue | Ubn | | | | | | | | | | | | | | | | |

s d p

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| f: Lanthanic → | La | Ce | Pr | Nd | Pm | Sm | Eu | Gd | Tb | Dy | Ho | Er | Tm | Yb |
| f: Actinic → | Ac | Th | Pa | U | Np | Pu | Am | Cm | Bk | Cf | Es | Fm | Md | No |
| g | Ubu | Ubb | Ubt | Ubq | Ubp | Ubh | | | | | | | | |

អលោហៈ
ដូច្នេះ

អាម៉ូញ៉ាក់ជាប្រតិករកំណត់

បរិមាណអ៊ុយរេកើតគឺ : $\frac{37.50}{2}\text{mol} \times 60\text{g.mol}^{-1} = 1125.00\text{g}$

បរិមាណធាតុគីមីដែលនីសល់: $7.25\text{mol} \times 44\text{g.mol}^{-1} = 319.00\text{g}$

ឧទា.22៖

ប្រតិកម្មរវាងអាលុយមីញ៉ូមជាមួយដែក( )អុកស៊ីតជាប្រតិកម្មបញ្ចេញកម្ដៅ តាមលំនាំសមីការខាងក្រោម

$2\text{Al(s)} + \text{Fe}_2\text{O}_3\text{(s)} \rightarrow 2\text{Fe} + \text{Al}_2\text{O}_3$

ក.តើគណនាបរិមាណ$\text{Al}_2\text{O}_3$ទទួលបាន បើគេប្រើអាលុយមីញ៉ូម124g ឲ្យមានប្រតិកម្មជាមួយដែក( III )អុកស៊ីត601g។

ខ. តើប្រតិករលើសនៅសល់ប៉ុន្មាន ក្រោយប្រតិកម្មចប់

ប្រតិកម្មរវាងអាលុយមីញ៉ូមជាមួយដែក( )អុកស៊ីតជាប្រតិកម្មបញ្ចេញកម្ដៅ តាមលំនាំសមីការខាងក្រោម

$2\text{Al(s)} + \text{Fe}_2\text{O}_3\text{(s)} \rightarrow 2\text{Fe} + \text{Al}_2\text{O}_3$

ក.តើគណនាបរិមាណ$\text{Al}_2\text{O}_3$ទទួលបាន បើគេប្រើអាលុយមីញ៉ូម124g ឲ្យមានប្រតិកម្មជាមួយដែក( III )អុកស៊ីត601g។

ខ. តើប្រតិករលើសនៅសល់ប៉ុន្មាន ក្រោយប្រតិកម្មចប់

ចម្លើយ៖

សមីការតាងប្រតិកម្មគីមី

$2\text{Al(s)} + \text{Fe}_2\text{O}_3\text{(s)} \rightarrow 2\text{Fe} + \text{Al}_2\text{O}_3$

គណនាចំនួនម៉ូល

$n_{\text{Al}} = \frac{124\text{g}}{27\text{g/mol}} = 4.59\text{ mol}$

$n_{\text{Fe}_2\text{O}_3} = \frac{601\text{g}}{160\text{g/mol}} = 3.75\text{mol}$

តាមសមីការតាងប្រតិកម្មគីមី

2mol Al ត្រូវការ 1mol $\text{Fe}_2\text{O}_3$ 2mol ដែក

4.59 mol Al ត្រូវការ $\frac{4.59\text{ mol}}{2}$ $\text{Fe}_2\text{O}_3$ ឲ្យ 4.59 mol ដែក $+ \frac{4.59\text{ mol}}{2}$ $\text{Al}_2\text{O}_3$

$\Rightarrow$ចំនួនម៉ូលរបស់ $\text{Fe}_2\text{O}_3$ សល់គឺ $3.75\text{mol} - \frac{4.59\text{ mol}}{2} = 1.46\text{mol}$

បរិមាណរបស់ $\text{Al}_2\text{O}_3$ ទទួលបានគឺ$2.3mol \times 102g/mol = 234.6g$

បរិមាណរបស់ $\text{Fe}_2\text{O}_3$ សល់គឺ$1.46mol \times \frac{160g}{mol} = 233.6g$

$n_{Fe} = \frac{280}{56} mol = 5mol$

$n_{O_2} = \frac{192}{32} mol = 6mol$

**តាមសមីការតាងប្រតិកម្មគឺមី**

| | | |
|---|---|---|
| 3Fe | $+ 2O_2$ | $\rightarrow Fe_3O_4$ |
| 3mol | + 2mol | $\rightarrow 1mol Fe_3O_4$ |
| 5mol | + x mol | $\rightarrow 5/3mol Fe_3O_4$ |

$\Longrightarrow x = \frac{5 \times 2}{3}$

**ដូច្នេះ ចំនួនម៉ូលអុកស៊ីហ្សែនដែលចូលរួមប្រតិកម្ម**( 10/3 )**តិចជាង ចំនួនម៉ូលរបស់អុកស៊ីហ្សែនដែលឲ្យ**( $6mol$ )។

$\Longrightarrow$ Fe **ជាប្រតិករកំណត់**

**ចំនួនអុកស៊ីហ្សែនដែលសល់គឺ** $6mol - \frac{10}{3} mol = 2.7mol$

$m_{Fe_3O_4} = \frac{5}{3mol} \times 232g.mol^{-1} = 386.66g$

$m_{O_2}$**សល់** $= 2.7mol \times 32g.mol^{-1} = 86.4g$

**ប្រធានលំហាត់៖**

**ក. គណនាបរិមាណដែកម៉ាញេទិចដែលទទួលបានពីប្រតិកម្មរវាង** $280g$ **ដែកជាមួយ** $192g$ **អុកស៊ីហ្សែន**

**ខ. គណនាបរមាណធាតុដែលនៅសល់ក្រោមប្រតិកម្ម។**

**មេរៀនទី២**

# ទម្រង់អាតូម និង តារាងខួបនៃធាតុគីមី

## Atomic structure and Periodic table of elements

## គោលការណ៍លើកលែងរបស់ Pauli :

### 1. ចំនួនកង់ទិច:

**ចំនួនកង់ទិចមេ(n): បង្ហាញពីថាមពលអេឡិចត្រុងក្នុងស្រទាប់នីមួយៗ ឬវាតំណាងឲ្យស្រទាប់អេឡិចត្រុង ជាមួយៈ**

| $n \in \mathbb{N}^*$ (ជាចំនួនគត់ធម្មជាតិ) | 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|---|
| សន្មតឈ្មោះស្រទាប់អេឡិចត្រុង | K | L | M | N | O | P | Q |

**ចំនួនកង់ទិចអ័រប៊ីតាល់(l): បង្ហាញពីរូបសណ្ឋានអេឡិចត្រុងក្នុងស្រទាប់រងនីមួយៗ ឬវាតំណាងឲ្យស្រទាប់រងអេឡិចត្រុង**

| $l \in \mathbb{N}$ (ជាចំនួនគត់) | 0 | 1 | 2 | 3 | 4 |
|---|---|---|---|---|---|
| សន្មតឈ្មោះស្រទាប់រងអេឡិចត្រុង | s | p | d | f | g |

ចំពោះមួយតម្លៃនៃ n នោះ l មាន n តម្លៃ

**ឧទា.1៖**

ពេល $n = 1 \Rightarrow l$ មាន 1 តម្លៃ គឺ $l = 0$ ជាអ័រប៊ីតាល់ 1s

ពេល $n = 2 \Rightarrow l$ មាន 2 តម្លៃ គឺ $l = 0, 1$ ជាអ័រប៊ីតាល់ 2s, 2p

ពេល $n = 3 \Rightarrow l$ មាន 3 តម្លៃ គឺ $l = 0, 1, 2$ ជាអ័រប៊ីតាល់ 3s, 3p, 3d

$2n^2$ ជារូបមន្តស្រទាប់ឆ្អែតអេឡិចត្រុង

ស្រទាប់ K (n = 1) អាចមាន២អេឡិចត្រុងអតិបរិមា

ស្រទាប់ M (n = 3) អាចមាន១៨អេឡិចត្រុងអតិបរិមា

ស្រទាប់ O (n = 5) អាចមាន ៥០ អេឡិចត្រុងអតិបរិមា

**ឧទា.1៖**

ពេល $n = 2$ (L) $\Rightarrow l$ មាន២តម្លៃ គឺ $l = 0(s), 1(p)$

$\Rightarrow$ L : 2s. 2p




អ័រប៊ីតាល់អាតូម គឺ គន្លងដែលអេឡិចត្រុងចរក្នុងលំហរ ថតសម្រាប់ដាក់អេឡិចត្រុង

ពេល $n = 1, \ l = 0 \Rightarrow m_l$ មាន $2 \times 0 + 1$តម្លៃ គឺ $m_l = 1$

មានន័យថាមាន1 អ័រប៊ីតាល់

តើ 1 អ័រប៊ីតាល់បិតក្នុងទម្រង់បែប



ពេល $n = 3, \ l = 0 \Rightarrow m_l$ មាន $2 \times 0 + 1$តម្លៃ (មាន1 អ័រប៊ីតាល់)




$l = 1 \Rightarrow m_l$ មាន $2 \times 1 + 1$តម្លៃ (មាន3 អ័រប៊ីតាល់)




$l = 2 \Rightarrow m_l$ មាន $2 \times 2 + 1$តម្លៃ (មាន5 អ័រប៊ីតាល់)



ពេល $n = 4$, $l = 0 \Rightarrow m_l$ មាន $2 \times 0 + 1$តម្លៃ (មាន1 អ័របីតាល់)

$l = 1 \Rightarrow m_l$ មាន $2 \times 1 + 1$តម្លៃ (មាន3 អ័របីតាល់)

$l = 2 \Rightarrow m_l$ មាន $2 \times 2 + 1$តម្លៃ (មាន5 អ័របីតាល់)

$l = 3 \Rightarrow m_l$ មាន $2 \times 3 + 1$តម្លៃ (មាន7 អ័របីតាល់)

$n = 4$ មាន16 អ័របីតាល់ $\Rightarrow 2 \times 4^2 = 32e^-$




$e_1 : n = 1, l = s = 0, m_l = 0, m_s = +\frac{1}{2}$

$e_1 : n = 1, l = s = 0, m_l = 0, m_s = -\frac{1}{2}$

$l = 0 \Rightarrow m_l$ មាន $2 \times 0 + 1$តម្លៃ គឺ $m_l = 0$

$l = 1 \Rightarrow m_l$ មាន $2 \times 1 + 1$តម្លៃ គឺ $m_l = -1,\ 0, +1$

$l = 3 \Rightarrow m_l$ មាន $2 \times 3 + 1$តម្លៃ គឺ $m_l = -3, -2, -1, 0, +1, +2, +3$

$Na(z = 11)$មាន$11e^- = 1s^2 2s^2 2p^6 3s^1$

$\Rightarrow\ K(1s^2)\ \ L(2s^2 2p^6)\ \ \ M(3s^1 3p^0 3d^0)$

↑↓   ↑↓ ↑↓ ↑↓ ↑↓   ↑

Diamagnetic ជាអាតូមឬម៉ូលេគុលដែលមានស្ពីនគូ

Paramagnetic ជាអាតូមឬម៉ូលេគុលដែលមានស្ពីនសេស

**ចំនួនកង់ទិចម៉ាញេទិច($m_l$):** បង្ហាញពីលំហរដែលអាចរកឃើញអេឡិចត្រុង ឬជាថតអេឡិចត្រុង។ ១តម្លៃរបស់ $m_l$ តាងឲ្យ ១ អ័របីតាល់ ដែលតម្លៃនេះស្មើនឹង $2l + 1$ របស់ $l$។ តម្លៃរបស់ គឺ $m_l \in \mathbb{Z}$ យកពី $-l, 0, +l$

**ឧទា.2៖**

ពេល $n = 1$, $l = 0 \Rightarrow m_l$ មាន $2 \times 0 + 1$តម្លៃ គឺ $m_l = 1$ មានន័យថាមាន1 អ័របីតាល់(AO)

ពេល $n = 2$, $l = 0 \Rightarrow m_l$ មាន $2 \times 0 + 1$តម្លៃ គឺ $m_l = 1$ មានន័យថាមាន1 អ័របីតាល់

$l = 1 \Rightarrow m_l$ មាន $2 \times 1 + 1$តម្លៃ គឺ $m_l = 3$ មានន័យថាមាន 3 អ័របីតាល់

ពេល $n = 3$, $l = 0 \Rightarrow m_l$ មាន $2 \times 0 + 1$តម្លៃ គឺ $m_l = 1$ មានន័យថាមាន1 អ័របីតាល់

$l = 1 \Rightarrow m_l$ មាន $2 \times 1 + 1$តម្លៃ គឺ $m_l = 3$ មានន័យថាមាន 3 អ័របីតាល់

$l = 2 \Rightarrow m_l$ មាន $2 \times 2 + 1$តម្លៃ គឺ $m_l = 5$ មានន័យថាមាន 5 អ័របីតាល់

**ចំនួនកង់ទិចស្ពីន($m_s$):** បង្ហាញចលនាស្វ័យរង្វិលនៃអេឡិចត្រុងជុំវិញណ្វៃយ៉ូ។ ជានិច្ចកាលតម្លៃ $m_s$ គឺស្មើនឹង $\pm\frac{1}{2}$

$m_s = +\frac{1}{2}$ ហៅថាស្ពីនស្រប តាងដោយ ↑

$m_s = -\frac{1}{2}$ ហៅថាស្ពីនច្រាស តាងដោយ ↓

## 2. គោលការណ៍លើកលែង Pauli:

**ពំនោល១** " ២អេឡិចត្រុងមិនអាចមានតម្លៃនៃចំនួនកង់ទិចទាំង៤ដូចគ្នានុះទេ"

**ឧទា.3៖**

អាតូមអេល្យូមមានលេខលំដាប់២ មានន័យថាវាមាន២អេឡិចត្រុង ដែលអេឡិចត្រុងតាងដោយ $e_1$, $e_2$ ក្នុង $1s$

ចំពោះអេឡិចត្រុងទី១ $e_1$ មាន $n = 1, l = 0, m_l = 0, m_s = +\frac{1}{2}$

ចំណែកអេឡិចត្រុងទី២ $e_2$ មាន $n = 1, l = 0, m_l = 0, m_s = -\frac{1}{2}$

**ឧទា.4៖**

អាតូមលីចូម មាន៣អេឡិចត្រុង( ស្រទាប់ទី១មាន២អេឡិចត្រុង, ស្រទាប់ទី២មាន១អេឡិចត្រុង ) $e_1, e_2, e_3$

$e_1$មាន $n = 1, l = 0, m_l = 0, m_s = +\frac{1}{2}$

$e_2$ មាន $n = 1, l = 0, m_l = 0, m_s = -\frac{1}{2}$

$e_3$ មាន $n = 2, l = 0, m_l = 0, m_s = +\frac{1}{2}$

**ពំនោល២** " ការបំពេញអេឡិចត្រុងក្នុងអ័របីតាល់អាតូម ត្រូវបំពេញពីថាមពលទាបទៅខ្ពស់"

គឺ$1s > 2s > 2p > 3s > 3p > 4s > 3d > 4p$ … … … .

## គោលការណ៍បំពេញអេឡិចត្រុង

**ពំនោល**"ការបំពេញអេឡិចត្រុងក្នុងអ័របីតាល់អាតូម ត្រូវបំពេញតាមតម្លៃផលបូក n + l តូចទៅធំ ករណីតម្លៃផលបូកស្មើគ្នា អេឡិចត្រុងបំពេញទៅលើ n ដែលមានតម្លៃតូចមុន"




**ឧទា.5៖**

លីចូម$(z = 3)$ $1s^2 2s^1$

សូដ្យូម $(z = 11)$ $1s^2 2s^2 2p^6 3s^1$

ក្លរ $(z = 17)$ $1s^2 2s^2 2p^6 3s^2 3p^5$

នេអុង $(z = 11)$ $1s^2 2s^2 2p^6$

Br $(z = 35)$ $[Ar]4s^2 3d^{10} 4p^6$

Hg $(z = 80)$ $[Xe]6s^2 4f^{14} 5d^{10}$

Lu $(z = 71)[Xe]6s^2 4f^{14} 5d^1$

K $(z = 19)$ $1s^2 2s^2 2p^6 3s^2 3p^6 4s^1$

Cu $(z = 29)$ $[Ar]4s^2 3d^9$

$= [Ar]4s^1 3d^{10}$

**ឧទា.4៖**

Configuration structure **របាយអេឡិចត្រុង ឬ ទម្រង់អេឡិចត្រុង ឬ រូបសណ្ឋានអេឡិចត្រុង**

$Og(z=118)1s^2 \mid 2s^22p^6 \mid 3s^23p^6 \mid 4s^23d^{10}4p^6 \mid 5s^24d^{10}5p^6 \mid 6s^24f^{14}5d^{10}6p^6 \mid 7s^25f^{14}6d^{10}7p^6$

$[He]^2$

$[Ne]^{10}$

$[Ar]^{18}$

$[Kr]^{36}$

$[Xe]^{54}$

$[Rn]^{86}$

**របាយអេឡិចត្រុងក្នុងស្រទាប់និមួយៗ**

| | | | |
|---|---|---|---|
| **Og** | Q | = | 8 |
| | P | = | 18 |
| | O | = | 15 |
| | N | = | 32 |
| | M | = | 18 |
| | L | = | 8 |
| | K | = | 2 |

⟹ **ការសរសេររបាយអេឡិចត្រុងដោយប្រើទម្រង់ឧស្ម័នកម្រ**

$Og(z=118)[Rn]7s^25f^{14}6d^{10}7p^6$

**ឧទា.5៖**

**ចូរសរសេររបាយអេឡិចត្រុងរបស់ ធាតុគីមីដែលមានលេខលំដាប់៧៥ ដោយប្រើទម្រង់ឧស្ម័នកម្រ។**

$X(z=75)[Xe]6s^24f^{14}5d^5$

**ឧទា.6៖**

$Rh(z=45) = 45e^- : 1s^2 \mid 2s^22p^6 \mid 3s^23p^6 \mid 4s^23d^{10}4p^6 \mid 5s^24d^5$

$Rh = [Kr]5s^24d^5$

[He]

[Ne]

[Ar]

[Kr]

**ឧទា.7៖**

$Hg\ (z=80) = 80e^- : [Xe]6s^24f^{14}5d^{10}$

$Ge\ (z=32) = 32e^- : [Ar]4s^23d^{10}4p^2$

$Cr(z=24) = 24e^- : [Ar]4s^23d^4 = [Ar]4s^13d^5$ **ស្រទាប់រងពាក់កណ្ដាលឆ្អែត**

$Cu(z=29) = 29e^- : [Ar]4s^23d^9 = [Ar]4s^13d^{10}$**ស្រទាប់រងឆ្អែត**

$Pd\ (z=46) = 48e^- : [Kr]5s^24d^8 = [Kr]4d^{10}$

**The Hund's law**

"នៅក្នុងអ័រប៊ីតាល់អាតូមមួយដែលមានថាមពលស្មើគ្នា អេឡិចត្រុងបំពេញទៅលើអ័រប៊ីតាល់ ត្រូវបំពេញស្ពីនស្របជាមុន បន្ទាប់មកស្ពីនច្រាស"

"បំពេញទៅលើអ័រប៊ីតាល់ ត្រូវបំពេញដោយលៃយ៉ាងណាឲ្យតម្លៃផលបូកស្ពីនអតិបរមា"

**ឧទា.៨៖**

អាហ្សូត (N(z-7)) $1s^2\ 2s^2\ 2p^3$

ក្លរ (Cl(z=17)) $[Ne]\ 3s^2\ 3p^5$

ទង់ដែង (Cu(z=29)) $[Ar]\ 4s^2\ 3d^9$

ក្រូម (Cr(z=24)) $[Ar]\ 4s^2\ 3d^4$




⇒ អេឡិចត្រុងវ៉ាឡង់ ជាអេឡិចត្រុងស្រទាប់ក្រៅបង្អស់

វ៉ាឡង់ ជាអេឡិចត្រុងសេរីនៅស្រទាប់ក្រៅបង្អស់

សណ្ឋានគ្រឹះ៖ ជាសណ្ឋានដំបូងរបស់អេឡិចត្រុង

សណ្ឋានភ្ញោច ជាសណ្ឋានដែលអេឡិចត្រុងនៅស្រទាប់ក្រៅបង្អស់ ផ្លាស់ទីទៅស្រទាប់មួយផ្សេងទៀត

**ឧទា.9៖**

$N(z = 7){:}\ [He]2s^2 2p^3$

$Cl(z=17){:}\ [Ne]\ 3s^2 3p^5$

$Cl_2O_3$

$Cl_2O_5$

$Cl_2O_7$

សណ្ឋានគ្រឹះ៖ $[Ne]^{10}$

សណ្ឋានភ្ញោចទី១ $[Ne]^{10}$

សណ្ឋានភ្ញោចទី២ $[Ne]^{10}$

សណ្ឋានភ្ញោចទី៣ $[Ne]^{10}$



**ឧទា.10៖**

$Cu(z = 29){:}\ [Ar]4s^2 3d^9 \Longrightarrow [Ar]4s^1 3d^{10}$ ជាករណីស្រទាប់រងឆ្អែត

$Ag(z = 47){:}\ [Kr]5s^2 4d^9 \Longrightarrow [Kr]5s^1 4d^{10}$ ជាករណីស្រទាប់រងឆ្អែត

$Cr(z = 24){:}\ [Ar]4s^2 3d^4 \Longrightarrow [Ar]4s^1 3d^5$ ជាករណីស្រទាប់រងពាក់កណ្ដាលឆ្អែត

$W(z = 73){:}\ [Xe]6s^2 4f^{14} 3d^4 \Longrightarrow [Xe]6s^1 4f^{14} 3d^5$ ជាករណីស្រទាប់រងពាក់កណ្ដាលឆ្អែត

$Pd(z = 46){:}\ [Kr]5s^2 4d^8 \Longrightarrow [Kr]4s^0 3d^{10}$ ជាករណីពិសេស

## តារាងខួបនៃធាតុគីមី

ខួប →

ក្រុម ↓

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| H | | | | | | | | | | | | | | | | | He |
| Li | Be | | | | | | | | | | | B | C | N | O | F | Ne |
| Na | Mg | | | | | | | | | | | Al | Si | P | S | Cl | Ar |
| K | Ca | Sc | Ti | V | Cr | Mn | Fe | Co | Ni | Cu | Zn | Ga | Ge | As | Se | Br | Kr |
| Rb | Sr | Y | Zr | Nb | Mo | Tc | Ru | Rh | Pd | Ag | Cd | In | Sn | Sb | Te | I | Xe |
| Cs | Ba | Lu | Hf | Ta | W | Re | Os | Ir | Pt | Au | Hg | Tl | Pb | Bi | Po | At | Rn |
| Fr | Ra | Lr | Rf | Db | Sg | Bh | Hs | Mt | Ds | Rg | Cn | Nh | Fl | Mc | Lv | Ts | Og |
| Uue | Ubn | | | | | | | | | | | | | | | | |

s d p

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| f – Lanthanic | La | Ce | Pr | Nd | Pm | Sm | Eu | Gd | Tb | Dy | Ho | Er | Tm | Yb |
| f – Actinic | Ac | Th | Pa | U | Np | Pu | Am | Cm | Bk | Cf | Es | Fm | Md | No |
| g | Ubu | Ubb | Ubt | Ubq | Ubp | Ubh | | | | | | | | |

អលោហៈ

អំផូទែ

លោហៈ

ឧស្ម័នកម្រ

---

**ថត** ជាប្រអប់បួនជ្រុងសម្រាប់ដាក់ធាតុគីមី

**និមិត្តសញ្ញា** ជាអក្សរតំណាងឲ្យធាតុគីមី

ដែលតាងដោយឈ្មោះធាតុគីមី **ឧទា.** អ៊ីដ្រូសែន (Hydrogen (H)) ឬ

ឈ្មោះអ្នកប្រាជ្ញ **ឧទា.** Neil Borh (Bh), Rf, Md ឬ

ឈ្មោះប្រទេស ឬតំបន់ **ឧទា.** Californium(Cf) Polonium (Po) Meconium(Mc)

**ប្លុក** ជាសំណុំធាតុគីមី ដែលមានអ័របីតាល់អាតូមចុងក្រោយបង្អស់ដូចគ្នា

**ឧទា.11៖** លីចូម ([He]$2s^1$) កាល់ស្យូម ([Ar]$4s^2$) ប៉ូតាស្យូម ([Ar]$4s^1$)

**ឧទា.12៖** បរ ([He]$2s^2 2p^1$) ផូស្វ័រ ([Ne]$3s^2 3p^3$ ≪) ប្រូម ([Ar]$4s^2 3d^{10} 4p^5$)

ប្លុកមានបួនប្លុក គឺប្លុក-s ប្លុក-p ប្លុក-d និង ប្លុក-f

**ក្រុម** ជាសំណុំធាតុគីមី ដែលតំរៀបតាមជួរឈរ (ធាតុគីមីទាំងអស់មានលក្ខណៈគីមីប្រហាក់ប្រហែលគ្នា)

**ឧទា.13៖** Li Na K ឋិតនៅក្នុងជួរឈរតែមួយ ព្រោះវាងាយនឹងបោះបង់១អេឡិចត្រុង ដើម្បីក្លាយជា $M^+$

ក្រុមនៃធាតុគីមីមានដូចជា៖

ក្រុម១ ហៅថា លោហៈអាល់កាឡាំង (Alkaline metals)

ក្រុម២ ហៅថា លោហៈអាល់កាលីណូទែរ៉ឺ (Alkaline earth metals)

ក្រុម៣ ដល់ក្រុម១២ ហៅថា ធាតុឆ្លង (Transition elements)

ក្រុម១៣ ហៅថា ក្រុមបរនិងអាលុយមីញ៉ូម (Boron & Aluminum groups)

ក្រុម១៤ ហៅថា ក្រុមកាបូននិងស៊ីលីស្យូម (Carbon & Silicon groups)

ក្រុម១៥ ហៅថា ក្រុមអាហ្សូតនិងផូស្វ័រ (Nitrogen & Phosphorus groups)

ក្រុម១៦ ហៅថា ក្រុមអុកស៊ីហ្សែននិងស្ពាន់ធ័រ ឬឆាលកូហ្សែន (Chalcogen)

ក្រុម១៧ ហៅថា ក្រុមអាឡូហ្សែន (Halogen)

ក្រុម១៨ ហៅថា ក្រុមឧស្ម័នកម្រ (Noble gas)

X(z=15) $[Ne]3s^2 3p^3$

Y(z=30) $[Ar]4s^2 3d^{10}$

Z(z=56) $[Xe]6s^2$

M(z=27) $[Ar]4s^2 3d^7$

N(z=80) $[Xe]6s^2 4f^{14} 5d^{10}$

$Block - d, Group\ 12, period\ 6^{th}$

*សម្គាល់៖*

ដើម្បីធ្វើដឹងពីលេខក្រុមនៃធាតុគីមី ដោយមិនចាំបាច់មើលតារាងខួប យើងត្រូវចាំ៖

លេខក្រុមនៃធាតុដែលឋិតក្នុងប្លុក s = ចំនួន $e^-$ នៅស្រទាប់ក្រៅបង្អស់

លេខក្រុមនៃធាតុដែលឋិតក្នុងប្លុក d = ចំនួន $e^-$ នៅស្រទាប់ក្រៅបង្អស់ + 2

លេខក្រុមនៃធាតុដែលឋិតក្នុងប្លុក p = ចំនួន $e^-$ នៅស្រទាប់ក្រៅបង្អស់ + 12

**ឧទា.14៖**

M ជាធាតុគីមីមួយមានលេខអាតូម 7៧២

ក. ចូរកំណត់ទីតាំងរបស់វាក្នុងតារាងខួប

ខ. កំណត់លក្ខណៈរបស់ វា

**ចម្លើយ**

សរសេររបាយអេឡិចត្រុង

M(z=72) $[Xe]6s^2 4f^{14} 5d^2$

ក. វាជាធាតុដែលឋិតក្នុងប្លុក $- d$ ក្រុម ៤ ខួបទី៦

ខ. លក្ខណៈរបស់លោហៈឆ្លង

**ឧទា.15៖**

N ជាធាតុគីមីមួយមានលេខអាតូម ៩២

ក. ចូរកំណត់ទីតាំងរបស់វាក្នុងតារាងខួប

ខ. កំណត់លក្ខណៈរបស់ វា

**ចម្លើយ**

សរសេររបាយអេឡិចត្រុង

N(z=92) $[Rn]7s^2 5f^4$

ក. វាជាធាតុដែលឋិតក្នុងប្លុក $-f$ ខួបទី៧ អំបូរអាក់ទីនីត

ខ. លក្ខណៈរបស់លោហៈ ព្រោះវាមាន២អេឡិចត្រុងនៅស្រទាប់ក្រៅបង្អស់

**ឧទា.16៖**

R ជាធាតុគីមីមួយមានលេខអាតូម ១៦

ក. ចូរកំណត់ទីតាំងរបស់វាក្នុងតារាងខួប

ខ. កំណត់លក្ខណៈរបស់ វា

**ចម្លើយ**

សរសេររបាយអេឡិចត្រុង

R(z= 16) $[Ne]\ 3s^2 3p^4$

ក. វាជាធាតុដែលឋិតក្នុងប្លុក –p ក្រុម១៦ ខួបទី៣

ខ. លក្ខណៈរបស់អលោហៈ ព្រោះវាមាន ៦ អេឡិចត្រុងនៅស្រទាប់ក្រៅបង្អស់

**ឧទា.17៖**

R ជាធាតុគីមីមួយមានលេខអាតូម ៧៩

ក. ចូរកំណត់ទីតាំងរបស់វាក្នុងតារាងខួប

ខ. កំណត់លក្ខណៈរបស់ វា

**ឧទា.18៖**

X ជាធាតុគីមីមួយមានលេខលំដាប់៣៤

ក.ចូរសរសេររបាយអេឡិចត្រុងរបស់វា

ខ. ប្រាប់ពីទីតាំងរបស់នៅក្នុងតារាងខួប(មិនប្រើតារាង)

គ. ប្រាប់ពីលក្ខណៈរបស់ (ជាប៉ារ៉ាម៉ាញេទិចឬដ្យាម៉ាញេទិច)

**ឧទា.19៖**

គេថាធាតុអំផូទែ គឺជាធាតុដែលមានលក្ខណៈជាលោហៈផង អលោហៈផង តើត្រឹមត្រូវដែលឬទេ?

**ចម្លើយ**

មិនត្រឹមត្រូវទេ ឧទាហរណ៍

Al is the metalloid

$Al \longrightarrow Al^{3+} + 3e^-$ is metals

$Al + 3e^- \nrightarrow Al^{3-}$ is nonmetals តែ Al is the metalloid

ព្រោះ៖

$Al + 3H^+ \longrightarrow Al^{3+}$ $[Al(s) + HCl(l) \rightarrow AlCl_3(aq) + H_2(g)]$

$Al + 4OH^- \longrightarrow Al(OH)_4^- \rightleftharpoons AlO_2^- + H_2O$

$[Al(s) + NaOH(aq) + H_2O(l) \rightarrow NaAlO_2(aq) + H_2(g)]$

**សម្គាល់**

គ្រប់ធាតុអំផូទែ សមាសធាតុរបស់វាក៏ជាសមាសធាតុអំផូទែ តែគ្រប់សមាសធាតុអំផូទែ ធាតុរបស់វាមិនមែនជាធាតុអំផូទែនុះទេ។

**ឧទា.20៖**

តើធាតុគីមីណាមួយខាងក្រោមជាធាតុអំផូទែ ចូរសរសេរសមីការបញ្ជាក់?

ក. As  ខ. Pb  គ. Cr  ឃ. Sb  ង. Zn  ច. B

**ចំណាំ៖**

ពាក្យអាល់កាលី សំដៅលើបាសដែលរលាយក្នុងទឹក ឬបែកសព្វក្នុងទឹក.

**ខួប**

- ជាសំណុំធាតុគីមី ដែលតំរៀបតាមជួរដេក ឬមានចំនួនស្រទាប់អេឡិចត្រុងដូចគ្នា
- ក្នុងខួបនីមួយៗ វាចាប់ផ្តើមពីលោហៈអាល់កាឡាំង និងបញ្ចប់ដោយឧស្ម័នកម្រ

**ឧទា.21៖**

ខួបទី២រួមមាន៖ Li Be B C N O F Ne ឋិតនៅក្នុងជួដេកតែមួយ

**ឧទា.22៖**

ខួបទី៧ វាចាប់ផ្តើមពី ហ្វ្រង់ចូម ជាលោហៈអាល់កាឡាំង និងបញ្ចប់ដោយ អូហ្គាណេសុន ជាឧស្ម័នកម្រ

**ទម្រង់អេឡិចត្រុងនៃធាតុគីមី**

ក្នុងតារាងខួបនៃធាតុគីមី ធាតុគីមីទាំងអស់ត្រូវបានចាត់ថ្នាក់ដោយផ្អែកលើទម្រង់អេឡិចត្រុង ដូចជា៖

ក្រុមទី១និងទី២ មានទម្រង់អេឡិចត្រុងស្រទាប់ក្រៅគឺ $ns^1$ និង $ns^2$

ក្រុមទី៣និងទី១២ មានទម្រង់អេឡិចត្រុងស្រទាប់ក្រៅគឺ $ns^2(n-1)d^{1\rightarrow10}$

ក្រុមទី១៣និងទី១៨ មានទម្រង់អេឡិចត្រុងស្រទាប់ក្រៅគឺ $ns^2(n-1)d^{10}np^{1\rightarrow6}$

## លក្ខណៈនៃតារាងខួប

ការធ្វើចំណាត់ថ្នាក់នៃធាតុគីមីមានច្រើនវិធី ដូចជាសំពាធជុំវិញស្តង់ដា(standard ambient temperature (25°C) and pressure (100kpa)(SATP))និងសំពាធស្តង់ដា(STP(0°C) &(101.kPa)។ ក្នុងតារាងខួបធាតុដែលភាវរូបរាវមាន២គឺបារតនិងប្រូម និង១១ធាតុជាឧស្ម័ននៅ SATP។ ការធ្វើចំណាត់ថ្នាក់ទូទៅជា៖

- **ធាតុតំណាង(The main elements)** ជាធាតុដែលឋិតក្នុងប្លុក-s និងប្លុក-p
- **ធាតុឆ្លង(The transition elements)** ជាធាតុដែលឋិតក្នុងប្លុក-d
- **ឧស្ម័នកម្រ( The noble gases)** ជាធាតុដែលមានអេឡិចត្រុងស្រទាប់ក្រៅ $ns^2np^6$
- **អំបូរឡង់តានិដ(The Lanthanoids)** ជាធាតុដែលឋិតក្នុងប្លុក-f និងខួបទី៦
- **អំបូរអាក់ទីនិដ(The Actinoids)**ជាធាតុដែលឋិតក្នុងប្លុក-f និងខួបទី៧

## បម្រែបម្រួលលក្ខណៈរូបនៃធាតុគីមី

### 1. កាំអាតូម(Atomic radius)

ជាគម្លាត ពីចំណុចកណ្ដាលណ្វៃយ៉ូទៅអេឡិចត្រុងស្រទាប់ក្រៅដែលអង្កេត តម្លៃនេះប្រែប្រួលទៅតាមទំហំអាតូមឬអេឡិចត្រុងដែលអង្កេត។




ក្នុងក្រុមកាំអាតូមកើន ពីលើចុះក្រោម

ឧទា.23៖

| | Li | Na | K | Rb | Cs | Fr |
|---|---|---|---|---|---|---|
| $r_{atom}$ | 145pm | 190pm | 235pm | 248pm | 267pm | 290pm |

ក្នុងខួបពីឆ្វេងទៅស្តាំ កាំអាតូមថយចុះ

ឧទា.24៖

| | Li | Be | B | C | N | O | F | Ne |
|---|---|---|---|---|---|---|---|---|
| $r_{atom}$ | 145pm | 112pm | 98pm | 77pm | 92pm | 60pm | 73pm | 38pm |

### 2. កាំកូវ៉ាឡង់(covalent radius)

Covalent distance: ជាគម្លាតពីចំណុចកណ្ដាលណ្វៃយ៉ូនៃអាតូមទាំង២ នាំឲ្យកាំកូវ៉ាឡង់ស្មើកន្លះគម្លាតកូវ៉ាឡង់

ឧទា.25៖



**3. កាំ Van der Waal( Van der Waal radius)**

ជាពាក់កណ្ដាលអន្តរកម្ម ពីចំណុចកណ្ដាលណ្វៃយ៉ូនៃអាតូមទាំង២ មិនចងសម្ព័ន្ធតាមដែលអាចធ្វើបាន។

**ឧទា.26៖**




**4. ថាមពលអ៊ីយ៉ុងកម្ម( Ionization energy)**

ជាថាមពលសម្រាប់ផ្ដាច់១អេឡិចត្រុង ប្រសិនបើការផ្ដាច់១អេឡិចត្រុងជាអេឡិចត្រុងដំបូង គេហៅថា ថាមពលអ៊ីយ៉ុងកម្មទី១។ សមីការតាងប្រតិកម្មថាមពលអ៊ីយ៉ុងកម្មគឺ

$M \rightarrow M^{+} + 1e^{-}$ $I_1$ គិតជាគីឡូស៊ូលក្នុងមួយម៉ូល($kJ.mol^{-1}$)ឬ ជាអេឡិចត្រុងវ៉ុល(eV)

បើថាមពលអ៊ីយ៉ុងកម្មកាន់តែធំ នុះការផ្ដាច់អេឡិចត្រុងកាន់តែពិបាក

**ឧទា.27៖**

$Li \longrightarrow Li^{+} + 1e^{-}$ $I_1 = 520kJ.mol^{-1}$

$Li^{+} \longrightarrow Li^{2+} + 1e^{-}$ $I_2 = 7300kJ.mol^{-1}$

$Li^{2+} \longrightarrow Li^{3+} + 1e^{-}$ $I_3 = 11820kJ.mol^{-1}$

ដូច្នេះដើម្បីឲ្យលីចូមក្លាយជាអ៊ីយ៉ុង វាត្រូវការថាមពល

$Li \longrightarrow Li^{3+} + 3e^{-}$ $I = I_1 + I_2 + I_3 = 19640kJ.mol^{-1}$

**ឧទា.28៖**

$Al \longrightarrow Al^{+} + 1e^{-}$ $I_1 = 578kJ.mol^{-1}$

$Al^{+} \longrightarrow Al^{2+} + 1e^{-}$ $I_1 = 1817kJ.mol^{-1}$

$Al^{2+} \longrightarrow Al^{3+} + 1e^{-}$ $I_1 = 2745kJ.mol^{-1}$

ដូច្នេះដើម្បីឲ្យលីចូមក្លាយជាអ៊ីយ៉ុង វាត្រូវការថាមពល

$Al \longrightarrow Al^{3+} + 3e^{-}$ $I = I_1 + I_2 + I_3 = 5140kJ.mol^{-1}$

ដូច្នេះគេថាអាលុយមីញ៉ូម ងាយបោះបង់៣អេឡិចត្រុងជាងលីចូម ដែលបោះបង់៣អេឡិចត្រុង

## 5. ថាមពលចំណូលអេឡិចត្រុង( Electron Affinity)

ជាថាមពលដែលផ្ដល់ឲ្យអាតូមនៃធាតុគីមី ដើម្បីចាប់យកអេឡិចត្រុង។

**ឧទា. 29៖**

$Cl + 1e^- \longrightarrow Cl^-$ $EA = 349 kJ.mol^{-1}$

$F + 1e^- \longrightarrow F^-$ $EA = 324 kJ.mol^{-1}$

$Br + 1e^- \longrightarrow Br^-$ $EA = 239 kJ.mol^{-1}$

$O + 2e^- \longrightarrow O^{2-}$ $EA = 141 kJ.mol^{-1}$

$N + 3e^- \longrightarrow N^{3-}$ $EA = 7 kJ.mol^{-1}$

ដូច្នេះ បើថាមពលចំណូលអេឡិចត្រុងកាន់តែធំ នុំះការចាប់យកអេឡិចត្រុងក៏កាន់តែងាយ

## 6. កម្រិតអេឡិចត្រូអវិជ្ជមាន( Electronegativity)

ជាថាមពល ដែលផ្ដល់ឲ្យអាតូមនៃធាតុគីមីមួយ មានលទ្ធភាពទាញយកគូអេឡិចត្រុងសម្ព័ន្ធមកដាក់ខាងខ្លួន។

**ឧទា. 30៖**

យើងមានធាតុគីមី A មានប្រតិកម្មជាមួយធាតុគីមី B បង្កើតជាម៉ូលេគុល AB

$A + B \longrightarrow AB$

សួរថា៖ តើធាតុគីមី A ជាអ៊ីយ៉ុងវិជ្ជមាន ធាតុគីមី B ជាអ៊ីយ៉ុងអវិជ្ជមាន ឬ
ធាតុគីមី A ជាអ៊ីយ៉ុងអវិជ្ជមានឬ ធាតុគីមី B ជាអ៊ីយ៉ុងវិជ្ជមាន
តែបើ យើងដឹងថា $\chi_A > \chi_B$ នុំះធាតុគីមី A ជាអ៊ីយ៉ុងអវិជ្ជមាន ធាតុគីមី B ជាអ៊ីយ៉ុងវិជ្ជមាន
និងផ្ទុយមកវិញបើយើងដឹងថា $\chi_A < \chi_B$ នុំះធាតុគីមី A ជាអ៊ីយ៉ុងវិជ្ជមាន ធាតុគីមី B ជាអ៊ីយ៉ុងអវិជ្ជមាន

### ការគណនាកម្រិតអេឡិចត្រូអវិជ្ជមាន

**តាម**Milliken

$0.336 \times \left(\frac{|\Delta H_I + \Delta H_{EA}|}{2}\right) - 0.165$ ដែល $\Delta H_I$ ជាអង់តាល់ពីអ៊ីយ៉ុងកម្ម $\Delta H_{EA}$ ជាអង់តាល់ពីចំណូលអេឡិចត្រុង

**តាម**Pauling

$|\chi_A - \chi_B| = \sqrt{\frac{D_{A-B} - \frac{1}{2}(D_{A-A} + D_{B-B})}{1eV}}$ ដែល $D_{A-B}$ ជាគម្លាតសម្ព័ន្ធ A-B $D_{B-B}, D_{A-A}$ ជាគម្លាតសម្ព័ន្ធB-B, A-A

**តាម**Pauling

$\chi = \frac{3590 Z_{eff}}{(r_{cov}/1pm)^2} + 0.744$ ដែល $Z_{eff}$ ផលនៃបន្ទុកណ្វៃយ៉ូ $r_{cov}$ ជាកាំកូវ៉ាឡង់

## សារៈសំខាន់នៃកម្រិតអេឡិចត្រូអវិជ្ជមាន

១.ធម្មជាតិនៃសម្ព័ន្ធរវាង ២ អាតូមអាចព្យាករណ៍ដោយភាពខុសគ្នានៃកម្រិតអេឡិចត្រូអវិជ្ជមាន

ក. $|\chi_A - \chi_B| = 0$ ជាសម្ព័ន្ធកូវ៉ាឡង់មិនប៉ូលែ ចន្លោះ $0 \leq |\chi_A - \chi_B| < 0.5$

ខ. $|\chi_A - \chi_B|$ តូច ជាមួយ $\chi_A > \chi_B$ ជាសម្ព័ន្ធកូវ៉ាឡង់ប៉ូលែ ចន្លោះ $0.5 < |\chi_A - \chi_B| < 1.9$

គ. $|\chi_A - \chi_B| = 1.9$ នុំះ 50% សម្ព័ន្ធកូវ៉ាឡង់និង 50%សម្ព័ន្ធអ៊ីយ៉ូនិច

ឃ. $|\chi_A - \chi_B| > 1.9$ ជាសម្ព័ន្ធអ៊ីយ៉ូនិច ចន្លោះ $|\chi_A - \chi_B| > 1.9$

ដូច្នេះគេអាចកំណត់ភាគរយនៃសម្ព័ន្ធអ៊ីយ៉ូនិចតាម Allred & Rochow គឺ

$$\text{Ionic }\% = 16|\chi_A - \chi_B| + 3.5|\chi_A - \chi_B|^2$$

២. លោហៈដែលមានកម្រិតអេឡិចត្រូអវិជ្ជមានតូច និងអលោហៈមានកម្រិតអេឡិចត្រូអវិជ្ជមានធំ

៣. បើ $\chi_O - \chi_A$ មានតម្លៃធំ នុំះអុកស៊ីតជាអុកស៊ីតបាស

**ឧទា. 31៖** $Na - O\left|\chi_{Na(0.9)} - \chi_{O(3.5)}\right| > 1.9$

$\chi_O - \chi_A$ មានតម្លៃតូច នុំះអុកស៊ីតជាអុកស៊ីតអាស៊ីដ

**ឧទា. 32៖** $C - O\left|\chi_{O(3.5)} - \chi_{C(2.55)}\right| < 0.95$

| Symbol | $r_{atom}$ | $r_{Cov}$ | $r_{Vdw}$ | $d$(g/cm³) | $T_{mp}$(°C) | $T_{bp}$(°C) | $E_{Ioniz}(eV)$ | $E_{aff}$ | $\chi$ | Cry. St. |
|---|---|---|---|---|---|---|---|---|---|---|
| H | 53pm | 38pm | 120pm | $8.9 \times 10^{-5}$ | -259.14 | -253.00 | 13.53 | $72.8kJ.mol^{-1}$ | 2.20 | Hexagonal |
| He | 31pm | 32pm | 140pm | $1.8 \times 10^{-4}$ | -272.20 | -268.90 | 24.47 | $0\ kJ.mol^{-1}$ | 0 | HCP |
| Li | 145pm | 134pm | 182pm | 0.53 | 180.50 | 1342.00 | 5.37 | $59.6kJ.mol^{-1}$ | 0.98 | BCC |
| Be | 112pm | 90pm | 153pm | 1.85 | 1278.00 | 2970.00 | 9.50 | $0\ kJ.mol^{-1}$ | 1.57 | HCP |
| B | 98pm | 82pm | 192pm | 2.34 | 2075.80 | 3926.80 | 8.33 | $26.7kJ.mol^{-1}$ | 2.04 | Rhombohedral |
| C | 77pm | 77pm | 170pm | 2.26 | 3550.00 | 4827.00 | 11.22 | $153.9kJ.mol^{-1}$ | 2.55 | S. Hexagonal |
| N | 92pm | 75pm | 155pm | $1.25 \times 10^{-3}$ | -210.00 | -195.80 | 14.48 | $7kJ.mol^{-1}$ | 3.04 | Hexagonal |
| O | 48pm | 66pm | 152pm | $1.4 \times 10^{-3}$ | -219.00 | -182.90 | 13.56 | $141kJ.mol^{-1}$ | 3.44 | Cubic |
| F | 73pm | 71pm | 147pm | $1.7 \times 10^{-3}$ | -219.67 | -188.11 | 18.60 | $328kJ.mol^{-1}$ | 3.98 | Cubic |
| Ne | 38pm | 69pm | 154pm | $9 \times 10^{-4}$ | -248.67 | -246.05 | 21.47 | $0\ kJ.mol^{-1}$ | 0 | FCC |
| Na | 190pm | 154pm | 227pm | 0.97 | 97.80 | 882.94 | 5.12 | $52.8kJ.mol^{-1}$ | 0.93 | BCC |
| Mg | 160pm | 130pm | 173pm | 1.74 | 650.00 | 1090.00 | 7.61 | $0\ kJ.mol^{-1}$ | 1.31 | HCP |
| Al | 143pm | 118pm | 184pm | 2.70 | 660.00 | 2518.82 | 5.95 | $42.5kJ.mol^{-1}$ | 1.61 | FCC |
| Si | 132pm | 111pm | 210pm | 2.33 | 1414.85 | 3265.00 | 8.12 | $133.6kJ.mol^{-1}$ | 1.90 | FCC |
| P | 128pm | 106pm | 180pm | 2.82 | 44.15 | 280.50 | 10.30 | $72.0kJ.mol^{-1}$ | 2.19 | BCC |
| S | 127pm | 102pm | 180pm | 2.07 | 112.80 | 444.67 | 10.31 | $200.0kJ.mol^{-1}$ | 2.58 | Orthorhombic |

| Symbol | $r_{atom}$ | $r_{Cov}$ | $r_{Vdw}$ | $d$ | $T_{mp}$(℃) | $T_{bp}$(℃) | $E_{Ioniz}(eV)$ | $E_{aff}(kJ.mol^{-1})$ | $\chi$ | Cry. St. |
|---|---|---|---|---|---|---|---|---|---|---|
| Cl | 99pm | 99pm | 175pm | $3.2\times10^{-3}$ | -100.98 | -34.60 | 12.96 | 349.00 | 3.16 | Orthorhombic |
| Ar | 71pm | 97pm | 188pm | $1.8\times10^{-3}$ | -189.34 | -185.85 | 15.68 | 0 | 0 | FCC |
| K | 235pm | 196pm | 275pm | 0.856 | 63.38 | 758.80 | 4.32 | 48.40 | 0.82 | BCC |
| Ca | 197pm | 174pm | 231pm | 1.55 | 842.00 | 1484.00 | 6,09 | 2.37 | 1.00 | FCC |
| Sc | 162pm | 144pm | 211pm | 2.99 | 1541.00 | 2836.00 | 6.57 | 18.10 | 1.36 | HCP |
| Ti | 147pm | 136pm | 0pm | 4.54 | 1660.00 | 3287.00 | 6.81 | 7.60 | 1.54 | HCP |
| V | 134pm | 125pm | 0pm | 6.11 | 1910.00 | 3407.00 | 6.76 | 50.60 | 1.63 | BCC |
| Cr | 130pm | 127pm | 0pm | 7.19 | 1907.00 | 2672.00 | 6.74 | 64.30 | 1.66 | BCC |
| Mn | 127pm | 139pm | 0pm | 7.21 | 1245.00 | 2061.99 | 7.40 | 0 | 1.55 | BCC |
| Fe | 126pm | 125pm | 0pm | 7.88 | 1539.00 | 2862.00 | 7.83 | 15.70 | 1.83 | BCC |
| Co | 123pm | 126pm | 0pm | 8.90 | 1493.00 | 2870.00 | 7.81 | 63.70 | 1.88 | HCP |
| Ni | 124pm | 121pm | 163pm | 8.90 | 1455.00 | 2915.00 | 7.61 | 112.00 | 1.91 | FCC |
| Cu | 128pm | 138pm | 140pm | 8.92 | 1084.00 | 2562.00 | 7.69 | 118.40 | 1.90 | FCC |
| Zn | 138pm | 131pm | 139pm | 7.13 | 419.50 | 906.00 | 9.35 | 0 | 1.65 | HCP |
| Ga | 141pm | 126pm | 187pm | 5.91 | 29.80 | 2203.00 | 5.97 | 28.90 | 1.81 | Orthorhombic |
| Ge | 123pm | 122pm | 211pm | 5.32 | 937.50 | 2833.00 | 7.85 | 119 | 2.01 | FCC |

| Symbol | $r_{atom}$ | $r_{Cov}$ | $r_{Vdw}$ | $d$ | $T_{mp}$(℃) | $T_{bp}$(℃) | $E_{Ioniz}(eV)$ | $E_{aff}(kJ.mol^{-1})$ | $\chi$ | Cry. St. |
|---|---|---|---|---|---|---|---|---|---|---|
| As | 139pm | 119pm | 185pm | 5.72 | 0 | 613.00 | 9.96 | 78.00 | 2.18 | Rhombohedral |
| Se | 140pm | 116pm | 190pm | 4.79 | 217.00 | 684.80 | 9.50 | 195.00 | 2.55 | Hexagonal |
| Br | 115pm | 114pm | 185pm | 3.14 | -7.25 | 58.80 | 11.80 | 324.60 | 2.96 | Orthorhombic |
| Kr | 88pm | 110pm | 202pm | $3.7\times10^{-3}$ | -157.37 | -153.40 | 13.94 | - | 3.00 | FCC |
| Rb | 248pm | 211pm | 303pm | 1.53 | 39.32 | 687.20 | 4.16 | 46.90 | 0.82 | BCC |
| Sr | 215pm | 192pm | 249pm | 2.54 | 777.00 | 1382.00 | 5.67 | 5.03 | 0.95 | FCC |
| Y | 178pm | 162pm | - | 4.47 | 1526.00 | 3338.00 | 6.50 | 29.60 | 1.22 | HCP |
| Zr | 160pm | 148pm | - | 6.51 | 1855.00 | 4409.00 | 6.00 | 41.10 | 1.33 | HCP |
| Nb | 146pm | 137pm | - | 8.58 | 2477.00 | 4927.00 | - | 86.10 | 1.60 | BCC |
| Mo | 139pm | 145pm | - | 10.22 | 2623.00 | 4639.00 | 7.35 | 71.90 | 2.16 | BCC |
| Tc | 136pm | 156pm | - | 11.49 | 2157.00 | 4265.00 | - | 52.00 | 1.90 | HCP |
| Ru | 134pm | 126pm | - | 12.41 | 2334.00 | 4077.00 | 7.50 | 101.00 | 2.20 | HCP |
| Rh | 134pm | 135pm | - | 12.41 | 1964.00 | 3727.00 | 7.70 | 109.70 | 2.28 | FCC |
| Pd | 137pm | 131pm | 163pm | 12.02 | 1555.00 | 2963.00 | 8.30 | 53.70 | 2.20 | FCC |
| Ag | 144pm | 153pm | 172pm | 10.49 | 961.80 | 2162.00 | 7.54 | 125.60 | 1.93 | FCC |
| Cd | 154pm | 148pm | 158pm | 8.64 | 319.10 | 766.80 | 8.95 | - | 1.69 | HCP |

| Symbol | $r_{atom}$ | $r_{Cov}$ | $r_{Vdw}$ | $d$ | $T_{mp}$(℃) | $T_{bp}$(℃) | $E_{Ioniz}(eV)$ | $E_{aff}(kJ.mol^{-1})$ | $\chi$ | Cry. St. |
|---|---|---|---|---|---|---|---|---|---|---|
| In | 166pm | 144pm | 193pm | 7.31 | 156.60 | 2072.00 | 8.95 | 28.90 | 1.78 | Tetragonal |
| Sn | 162pm | 141pm | 217pm | 7.29 | 231.93 | 2602.00 | 7.37 | 107.30 | 1.96 | Tetragonal |
| Sb | 159pm | 138pm | 206pm | 6.69 | 630.75 | 1587.00 | 8.35 | 103.20 | 2.05 | Rhombohedral |
| Te | 160pm | 135pm | 206pm | 6.25 | 449.55 | 987.80 | - | 190.20 | 2.10 | Hexagonal |
| I | 136pm | 133pm | 198pm | 4.94 | 113.55 | 184.35 | 10.40 | 295.20 | 2.66 | Orthorhombic |
| Xe | 108pm | 130pm | 216pm | $5.9 \times 10^{-3}$ | -11.80 | -108.10 | 12.08 | - | 2.6 | FCC |
| Cs | 267pm | 225pm | 343pm | 1.90 | 28.45 | 670.80 | 3.88 | 45.50 | 0.79 | BCC |
| Ba | 222pm | 198pm | 268pm | 3.5 | 727.00 | 1897.00 | 5.19 | 13.95 | 0.89 | BCC |
| Lu | 175pm | 160pm | - | 9.84 | 1663.00 | 3395.00 | - | 50.00 | 1.27 | HCP |
| Hf | 167pm | 150pm | - | 13.31 | 2233.00 | 4602.00 | - | - | 1.30 | HCP |
| Ta | 149pm | 138pm | - | 16.68 | 3017.00 | 5458.00 | - | 31.00 | 1.50 | Tetragonal |
| W | 141pm | 146pm | - | 19.26 | 3422.00 | 5555.00 | - | 78.60 | 2.36 | BCC |
| Re | 137pm | 159pm | - | 21.03 | 3180.00 | 5627.00 | - | 14.50 | 1.90 | HCP |
| Os | 135pm | 128pm | - | 22.59 | 3033.00 | 5597.00 | - | 106.10 | 2.20 | HCP |
| Ir | 136pm | 137pm | - | 22.56 | 2410.00 | 4130.00 | - | 151.00 | 2.20 | FCC |
| Pt | 139pm | 128pm | 175pm | 21.45 | 1768.00 | 3825.00 | 8.9 | 205.30 | 2.28 | FCC |

មេរៀនទី៣

# ទម្រង់ម៉ូលេគុល និង ការចងសម្ព័ន្ធ

## Molecule structure and bonding

## ១. ប្រភេទសម្ព័ន្ធ

សម្ព័ន្ធអ៊ីយ៉ុនិច : សម្ព័ន្ធដែលកើតឡើងពីការបោះបង់និងការចាប់យកអេឡិចត្រុង

សម្ព័ន្ធកូវ៉ាឡង់ : សម្ព័ន្ធដែលកើតឡើងពីការដាក់អេឡិចត្រុងហ៊ុនគ្នា (រួមគ្នា)

សម្ព័ន្ធលោហៈ : សម្ព័ន្ធដែលកើតពីការតំរៀបអាតូមលោហៈនិងលោហៈក្នុងទម្រង់ជាបង្គុំហាប់ណែន

សម្ព័ន្ធអ៊ីដ្រូហ្សែន : សម្ព័ន្ធដែលកើតពីអាតូមអ៊ីដ្រូហ្សែននិងអាតូមនៃធាតុគីមី ដែលមានកម្រិតអេឡិចត្រូអវិជ្ជមានធំក្នុងសូលុយស្យុង

សម្ព័ន្ធកូអ័រឌីណាស្យុង : សម្ព័ន្ធដែលកើតឡើងពីអាស៊ីដឡឺវីស និង បាសឡឺវីស

សម្ព័ន្ធ Van der Waal : សម្ព័ន្ធដែលកើតពីការធ្វើអន្តរកម្មរវាងម៉ូលេគុលនិងម៉ូលេគុលក្នុងសូលុយស្យុង

## ២. ការចងសម្ព័ន្ធគីមី

### A. បន្សំនៃធាតុគីមី

**១.ការថយចុះនៃថាមពល៖**

ពេលអាតូម២ចងសម្ព័ន្ធជាមួយគ្នា នុំះវានឹងបង្កើតនូវកម្លាំងទាញចូល និងច្រានចេញ(force of attraction and repulsion) ដោយសារ៖

2

សម្ព័ន្ធអ៊ីយ៉ុនិច : សម្ព័ន្ធដែលកើតឡើងពីការបោះបង់និងការចាប់យកអេឡិចត្រុង

ឧទា.៖ $2Na + Cl_2 \rightarrow 2NaCl$

$2Na \rightarrow 2Na^+ + 2e^-$

$Cl_2 + 2e^- \rightarrow 2Cl^-$




សម្ព័ន្ធកូវ៉ាឡង់ : សម្ព័ន្ធដែលកើតឡើងពីការដាក់អេឡិចត្រុងហ៊ុនគ្នា (រួមគ្នា)

ឧទា.៖ $H_2 + Cl_2 \rightarrow 2HCl$

$H - Cl$



សម្ព័ន្ធលោហៈ : សម្ព័ន្ធដែលកើតពីការតំរៀបអាតូមលោហៈនិងលោហៈក្នុងទម្រង់ជាបង្គុំហាប់ណែន



**សម្ព័ន្ធអ៊ីដ្រូសែន** : សម្ព័ន្ធដែលកើតពីអាតូមអ៊ីដ្រូសែននិងអាតូមនៃធាតុគីមី ដែលមានកម្រិតអេឡិចត្រូអវិជ្ជមានធំក្នុងសូលុយស្យុង






**សម្ព័ន្ធកូអ័រឌីណាស្យុង** : សម្ព័ន្ធដែលកើតឡើងពីអាស៊ីដឡឺវីស និង បាសឡឺវីស

**ឧទា.៖** ■$BF_3 + : NH_3 \rightarrow F_3B \leftarrow NH_3$

**សម្ព័ន្ធ Van der Waal** : សម្ព័ន្ធដែលកើតពីការធ្វើអន្តរកម្មរវាងម៉ូលេគុលនិងម៉ូលេគុលក្នុងសូលុយស្យុង




ក. ការទាញគ្នារវាងអេឡិចត្រុងនិងណ្វៃយ៉ូ

ខ. ការច្រានគ្នារវាងអេឡិចត្រុងនិងអេឡិចត្រុង

គ. ការច្រានគ្នារវាងណ្វៃយ៉ូនិងណ្វៃយ៉ូ




**ឧទា.1៖**

$H_2: H_a(e_a^-) + H_b(e_b^-) \Longrightarrow H : H$

$\Longrightarrow E_{H_2} = E_{a,e_a} + E_{b,e_b} + E_{b,e_a} + E_{a,e_b} - E_{a,b} - E_{e_a,e_b}$

## ២. ច្បាប់អដ្ឋតា

អាតូមនៃធាតុគីមីទាំងអស់ចាំបាច់ត្រូវតំរៀបអេឡិចត្រុងឲ្យបាន២ ឬ៨នៅស្រទាប់ក្រៅ ន៎ះវានឹងមានបេរភាពនិងមានថាមពលទាប។








### ៣. និមិត្តសញ្ញាឡឺវីស

ដើម្បីសរសេរនិមិត្តសញ្ញាឡឺវីសសម្រាប់ធាតុគីមីមួយ យើងសរសេរនិមិត្តសញ្ញារបស់ធាតុគីមីព័ទ្ធជុំវិញដោយចំណុចមួយចំនួនជាចំនួនអេឡិចត្រុងវ៉ាឡង់។ ទ្វេតា( គូ )អេឡិចត្រុងដាក់រួមគ្នាដោយ ២អេឡិចត្រុងត្រូវបានតាងដោយ ·· ឬដោយ –។ ២ឬ៣ទ្វេតាអេឡិចត្រុងដាក់រួមគ្នា ត្រូវបានហៅថាពហុសម្ព័ន្ធ( សម្ព័ន្ធ ២ជាន់ ឬ ៣ជាន់ ) និងតាងដោយ = (::) ឬ ≡ (:::) ។

**ឧទា.2៖**

ក្នុងការបង្កើតជាម៉ូលេគុលអ៊ីដ្រូហ្សែន



H· + ·H → H : H ឬ H – H

ក្នុងការបង្កើតជាម៉ូលេគុលអ៊ីដ្រូហ្សែនក្លរ



H· + ·Ċ̣l̤̇ : → H :Ċ̣l̤̇ :

ព្រោះ$\chi_{Cl} > \chi_H \Longrightarrow |\chi_H - \chi_{Cl}| = |2.2 - 3.16| = 0.96$

ក្នុងការបង្កើតជាម៉ូលេគុលអាហ្សូត



: N ⋮ + ⋮ N : → : N ⋮⋮ N : ឬ | N ≡ N |

## B. ទ្រឹស្តីអេឡិចត្រុងវ៉ាឡង់

- អេឡិចត្រុងវ៉ាឡង់នៃអាតូម អាស្រ័យលើចំនួនអេឡិចត្រុងនៅស្រទាប់ក្រៅ
- ទម្រង់អេឡិចត្រុងនៃឧស្ម័នកម្រមានបេរភាព ៨អេឡិចត្រុងនៅស្រទាប់ក្រៅ។ វាជាឧស្ម័ននិចល ជាហេតុនាំឲ្យវាមិនមានសមាសធាតុ។
- អាតូមដែលមិនមាន ៨អេឡិចត្រុងនៅស្រទាប់ក្រៅមានលក្ខណៈគីមីសកម្ម ពួកវាមានទំនោរដើម្បីឲ្យមាន ៨អេឡិចត្រុង។ ចំនួនអេឡិចត្រុងដែលចូលរួមក្នុងសកម្មភាពនេះជាអេឡិចត្រុងវ៉ាឡង់។
- មានវិធី ២យ៉ាងដែលអាតូមអាចមាន ៨អេឡិចត្រុងនៅក្នុងកម្រិតថាមពលស្រទាប់ក្រៅ៖

**១. បោះបង់ឬទទួលយក**

**ឧទា.2៖**




**២. ដាក់ហ៊ុនអេឡិចត្រុង**

ការដាក់អេឡិចត្រុងហ៊ុនគ្នាមាន ២ប្រភេទ

២.១. ការដាក់អេឡិចត្រុងនៃអាតូមទាំង២ ត្រូវបានបង្កើតដោយបែងចែកស្មើគ្នាក្នុងការចងសម្ព័ន្ធ។



**ឧទា.3៖**




២. គូអេឡិចត្រុងត្រូវបានផ្តល់ដោយអាតូមមួយ ហើយគូអេឡិចត្រុងនេះត្រូវបានប្រើរួមគ្នាដើម្បីបង្កើតសម្ព័ន្ធកូអ័រឌីណាស្យុង។




ដូច្នេះបន្សំរវាង២ ឬច្រើនអាតូម វាអាស្រ័យនឹងការចែកអេឡិចត្រុងនៅស្រទាប់ក្រៅ តាមរបៀបដែលអាតូមទាំងអស់ទទួលបាននូវទម្រង់ដូចឧស្ម័នកម្រ ដែលមានស្ថេរភាពក្នុងកម្រិតថាមពលទាបបំផុត

$A_2B_5$=

$N(z=7)[He]\ 2s^2 2p^3$

O(z = 8)




Valent electron is number electron in ouster shell

Valent electron = 8 – lone electron

N = 8 – 3 = 5

O = 8 – 2 = 6

P(z =15) $[Ne]\ 3s^2 3p^3 3d^0$




O(z = 8) $[He]\ 2s^2 2p^4$



## ៣. សម្ព័ន្ធអ៊ីយ៉ុនិច

A. **និយមន័យ៖**

ជាសម្ព័ន្ធ ដែលកើតឡើងពីការផ្ទេរអេឡិចត្រុងមួយឬច្រើន ពីអាតូមដែលមានកម្រិតអេឡិចត្រូអវិជ្ជមានតូចទៅអាតូមដែលមានកម្រិតអេឡិចត្រូអវិជ្ជមានធំ

ក្នុងសម្ព័ន្ធនេះ កើតពីកម្លាំងទំនាញអេឡិចត្រូស្តាទិច រវាងអ៊ីយ៉ុងដែលមានបន្ទុកអវិជ្ជមាន(អាញ៉ុង) ជាមួយអ៊ីយ៉ុងដែលមានបន្ទុកវិជ្ជមាន(កាចុង)។

**ឧទា.4៖**

សូដ្យូមក្លរ កកើតពីការបោះបង់អេឡិចត្រុងរបស់សូដ្យូមនិងការចាប់យកអេឡិចត្រុងនៃអាតូមក្លរ ដូច្នេះសម្ព័ន្ធរវាងអ៊ីយ៉ុងសូដ្យូមនិងអ៊ីយ៉ុងក្លរជាសម្ព័ន្ធអ៊ីយ៉ុនិច។

$Na(s) + Cl_2(g) \rightarrow Na^+(g), Cl^-(g) \rightarrow NaCl(s)$

**ឧទា.5៖**

ម៉ាញេស្យូមស៊ុលហ្វាត កើតពីបន្សំនៃកាចុងម៉ាញេស្យូម ជាមួយអាញ៉ុងស៊ុលហ្វាត៖

$Mg(s) + H_2SO_4(l) \rightarrow Mg^{2+}(aq), SO_4^{2-}(aq) + H_2(g)$

**លក្ខខណ្ឌ**

ដើម្បីឲ្យសម្ព័ន្ធអ៊ីយ៉ុនិចអាចសម្រេចបាន លុះត្រាតែ៖

**១.ចំនួនអេឡិចត្រុងវ៉ាឡង់៖**

សម្ព័ន្ធអ៊ីយ៉ុនិចអាចកើតមានចំពោះអាតូមមួយ ដែលមានអេឡិចត្រុងវ៉ាឡង់ ១, ២, ៣ ផ្សំជាមួយអាតូមមួយទៀតមានអេឡិចត្រុងវ៉ាឡង់ ៥, ៦, ៧។

ជាទូទៅអាតូមដែលមាន ១, ២, ៣អេឡិចត្រុងវ៉ាឡង់ ជាអាតូមឋិតនៅក្រុម ១, ២និងក្រុមទី១៣(លោហៈសកម្ម) ចំណែកអាតូមដែលមាន ៥, ៦, ៧អេឡិចត្រុងជាអាតូមឋិតនៅក្រុមទី១៥, ១៦, ១៧(អលោហៈសកម្ម)។

**ឧទា.6៖**

១.សម្ព័ន្ធនៃសូដ្យូមក្លរួ ជាសម្ព័ន្ធអ៊ីយ៉ុនិច ព្រោះវាបង្កើតឡើងពីអាតូមសូដ្យូមឋិតនៅក្រុម១និងអាតូមក្លរឋិតនៅក្នុងក្រុម១៧

២. អាលុយមីញ៉ូមភ្លុយអ័រួ ជាសម្ព័ន្ធអ៊ីយ៉ុនិច ព្រោះវាបង្កើតឡើងពីអាលុយមីញ៉ូមឋិតនៅក្រុម១៣និងភ្លុយអ័រឋិតនៅក្នុងក្រុម១៧

៣. កាល់ស្យូមអុកស៊ីត ជាសម្ព័ន្ធអ៊ីយ៉ុនិច ព្រោះវាបង្កើតឡើងពីកាល់ស្យូមឋិតនៅក្រុម២និងអុកស៊ីហ្សែនឋិតនៅក្នុងក្រុម១៦



**២. ភាពខុសគ្នានៃកម្រិតអេឡិចត្រូអវិជ្ជមាន**

សម្ព័ន្ធអ៊ីយ៉ុនិចអាចកើតឡើងពេលដែលផលសងនៃកម្រិតអេឡិចត្រូអវិជ្ជមានធំជាង ១.៩។

**ឧទា.7៖**

១.ប៉ូតាស្យូមក្លរួផ្សំពីប៉ូតាស្យូមមាន $\chi = 0.8$ និងក្លរមាន $\chi = 3.16$

$\Rightarrow |\chi_K - \chi_{Cl} = 0.8 - 3.16 = 2.66| > 1.9$

$\Rightarrow$ សម្ព័ន្ធនៃប៉ូតាស្យូមនិងក្លរជាសម្ព័ន្ធអ៊ីយ៉ុនិច

**៣. ការថយចុះនៃថាមពល**

សម្ព័ន្ធអ៊ីយ៉ុនិចអាចកើតឡើងអាស្រ័យការថយចុះភាគច្រើននៃថាមពល

ការផ្លាស់ប្តូរថាមពលត្រូវបានអនុវត្តន៍តាមជំហានខាងក្រោម៖

១. លំនឹងថាមពលស្មើនឹងថាមពលអ៊ីយ៉ុងកម្មពេលបម្លែងពីភាវរូបជាឧស្ម័ន អាតូមទៅជាកាចុង។

$A + \text{Ionisation energy} \rightarrow A^{n+} + ne^-$

**ឧទា.8៖**

$Na \rightarrow Na^+ + 1e^-$ $\qquad I_1 = 496 kJ.mol^{-1}$

២. លំនឹងថាមពលស្មើនឹងថាមពលចំណូលអេឡិចត្រុង ពេលដែលបូកបន្ថែមអេឡិចត្រុងនៅភាវរូបជាឧស្ម័ននៃអាតូមទៅជាអាញ៉ុង។

$A + ne^{-} \rightarrow A^{n-}$ + affinity energy

**ឧទា.9៖**

$Cl(g) + e^{-} \rightarrow Cl^{-}$ $E_a = 349 kJ.mol^{-1}$

## ៤. ថាមពលបណ្ដាញ

ថាមពលបណ្ដាញនៃសមាសធាតុក្រាមអ៊ីយ៉ុនិច ត្រូវបានកំណត់ដោយពិសោធតាមលំនាំ វដ្ត Born-Haber ។ វដ្តនេះជាមូលដ្ឋាននៃច្បាប់ Hess ដើម្បីបង្កើតជាក្រាមអ៊ីយ៉ុនិចដែលបន្សំផ្ទាល់ នៃធាតុគីមី ឬដោយលំនាំជំនួសតាមជំហានខាងក្រោម៖

១. ប្រតិករត្រូវបម្លែងជាឧស្ម័ន
២. អាតូមឧស្ម័នត្រូវបានបម្លែងជាអ៊ីយ៉ុង
៣. អ៊ីយ៉ុងឧស្ម័នផ្សំគ្នាបង្កើតជាសមាសធាតុអ៊ីយ៉ុនិច

**ឧទា.10៖ប្រតិកម្មផ្ទាល់រវាងប៉ូតាស្យូមជាមួយភ្លុយអ័របង្កើតជាប៉ូតាស្យូមភ្លុយអ័រប្រព្រឹត្តតាមលំនាំ៖**



$K(s) + \frac{1}{2}F_2(g) \rightarrow KF(s)$ $Na(s) + \frac{1}{2}Cl_2 \rightarrow NaCl(s) = \Delta H_{lattic}?$

១. បម្លែងភាវរូបរឹងទៅជាឧស្ម័ន ដែលត្រូវការថាមពលរំហើរ ( Enthalpy sublimation )

$K(s) \rightarrow K(g)$ $\Delta H_{sub} = 89.6 kJ.mol^{-1}$

២. បង្កើតជាកាចុង ដែលត្រូវការថាមពលបណ្ដាច់អេឡិចត្រុង

$K(g) \rightarrow K^{+}(g) + e^{-}$ $\Delta H_{ion} = 419.0 kJ.mol^{-1}$

៣. បម្លែងម៉ូលេគុលឧស្ម័នទៅជាអាតូមឧស្ម័ន ដែលត្រូវការថាមពលបំបែកកន្លះម៉ូលេគុល

$\frac{1}{2}F_2(g) \rightarrow F(g)$ $\Delta H_{diss} = 79.1 kJ.mol^{-1}$

៤. បង្កើតជាអាញ៉ុង ដែលត្រូវការថាមពលចាប់យកអេឡិចត្រុង

$F(g) + e^{-} \rightarrow F^{-}(g)$ $\Delta H_{aff} = 79.1 kJ.mol^{-1}$

៥.បន្សំកាចុងនិងអាញ៉ុង ដើម្បីបង្កើតម៉ូលេគុល ដែលត្រូវការថាមពលបណ្ដាញ

$K^{+}(g) + F^{-}(g) \rightarrow KF(s)$ $\Delta H_{lattice} = ?$

**តាមច្បាប់ Hess**

$\Delta H_f = \Delta H_{sub} + \Delta H_{ion} + \Delta H_{diss} + \Delta H_{aff} + \Delta H_{lattice}$

ដូច្នេះដើម្បីបង្កើតប៉ូតាស្យូមក្លួយអ៊័រតាមរយៈប្រតិកម្មផ្ទាល់គេត្រូវការលថាមពល

$-562.7\mathrm{kJ.mol^{-1}} = 89.6 + 419 + 79.1 + (-332.6) + (-\Delta H_{lattice})$

$\Delta H_{lattice} = 562.7 + 89.6 + 419 + 79.1 - 332 = 817.7\mathrm{kJ.mol^{-1}}$

| Name of com. | $\Delta H_{lattice}$ | Name of com. | $\Delta H_{lattice}$ | Name of com. | $\Delta H_{lattice}$ |
|---|---|---|---|---|---|
| NaCl | $769\mathrm{kJ.mol^{-1}}$ | MgO | $3414\mathrm{kJ.mol^{-1}}$ | LiI | $730\mathrm{kJ.mol^{-1}}$ |
| KCl | $701\mathrm{kJ.mol^{-1}}$ | CaO | $3414\mathrm{kJ.mol^{-1}}$ | $MgI_2$ | $1944\mathrm{kJ.mol^{-1}}$ |
| $MgCl_2$ | $2326\mathrm{kJ.mol^{-1}}$ | BaO | $3029\mathrm{kJ.mol^{-1}}$ | $BaI_2$ | $1831\mathrm{kJ.mol^{-1}}$ |
| $BaCl_2$ | $2033\mathrm{kJ.mol^{-1}}$ | NaBr | $732\mathrm{kJ.mol^{-1}}$ | $CaF_2$ | $2630\mathrm{kJ.mol^{-1}}$ |
| $Na_2O$ | $2481\mathrm{kJ.mol^{-1}}$ | $CaBr_2$ | $2132\mathrm{kJ.mol^{-1}}$ | $AlCl_3$ | $5492\mathrm{kJ.mol^{-1}}$ |

## ៥. លក្ខណៈទូទៅនៃសមាសធាតុអ៊ីយ៉ូនិច

### ៥.១. ធម្មជាតិគ្រាម (Crystalline nature)

ធាតុបង្កក្នុងគ្រាមអ៊ីយ៉ូនិចគឺជាអ៊ីយ៉ុង មិនមែនម៉ូលេគុលទេ។ អ៊ីយ៉ុងទាំងនេះត្រូវបានរៀបក្នុងទម្រង់ជាបណ្តាញអ៊ីយ៉ុងបិតលើទម្រង់គ្រាមរឹងក្នុងអ័ក្សវិមាត្រ៣ ដោយកម្លាំងទំនាញអ៊ីយ៉ុង



ឧទា.11៖

សូដ្យូមក្លរ បង្កើតបានជាបណ្តាញគ្រាមក្នុងទម្រង់ជាគូប ដែលអ៊ីយ៉ុងសូដ្យូមត្រូវបានហ៊ុំព័ទ្ធដោយអ៊ីយ៉ុងក្លរ ចំណែកអ៊ីយ៉ុងក្លរក៏ត្រូវបានហ៊ុំព័ទ្ធដោយអ៊ីយ៉ុងសូដ្យូម( ផលធៀបកាំកាចុងនិងអាញ៉ុង ស្មើ 0.508 )

### ៥.២. ចំណុចរលាយនិងចំណុចរំពុះ(Melting and boiling points)

ដោយកម្លាំងទំនាញអេឡិចត្រូស្តាទិចខ្លាំង ធ្វើឲ្យមានរប៉ឹងក្នុងបណ្តាញគ្រាម ដើម្បីបំបែកអ៊ីយ៉ុងចេញពីគ្នា ត្រូវប្រើកម្លាំងខ្លាំង។

ដូច្នេះសមាសធាតុអ៊ីយ៉ូនិចមានចំណុចរលាយនិងចំណុចរំពុះខ្ពស់។

### ៥.៣. រឹងនិងផុយ( Hard and brittle )

សមាសធាតុអ៊ីយ៉ូនិចមានភាពរឹងពីធម្មជាតិ ភាពរឹងនេះ បណ្តាលពីកម្លាំងទំនាញរវាងអ៊ីយ៉ុងដែលមានបន្ទុកផ្ទុយគ្នាក្នុងទីតាំងបិតនៅ។ ភាពផុយនៃគ្រាមរឹងបណ្តាលពីចលនានៃស្រទាប់គ្រាមផ្សេងៗទៀតរងនូវកម្លាំងចម្រានពីកម្លាំងខាងក្រៅពេលប្រឈមមុខគ្នា។

### ៥.៤. ភាពរលាយ( Solubility )

សមាសធាតុអ៊ីយ៉ូនិចងាយរលាយក្នុងធាតុរំលាយប៉ូលែ។

ទឹកជាធាតុរំលាយដ៏ប្រសើ ព្រោះវាមានតម្លៃឌីអេឡិចទ្រិចធំ

**៥.៥. ចម្លងអគ្គីសនី** (Electrical conductivity)

ក្រាមអ៊ីយ៉ូនិច មិនចម្លងអគ្គីសនីទេ គឺជាអ៊ីយ៉ុង មិនមែនម៉ូលេគុលទេ ព្រោះអ៊ីយ៉ុងទាំងនេះរងនូវកម្លាំងទំនាញអេឡិចត្រូស្តាទិច ធ្វើឲ្យវាបិតលើទីតាំងថេរនៅក្នុងបណ្តាញក្រាម។ នៅពេលដែល សមាសធាតុអ៊ីយ៉ូនិចរលាយក្នុងធាតុរំលាយប៉ូលែ អ៊ីយ៉ុងទាំងនោះអាចចល័តទៅរកអេឡិចត្រូតរៀងៗខ្លួន ដោយចម្លងចរន្តអគ្គីសនី។

**៥.៦.ប្រតិកម្មនៃអ៊ីយ៉ុង**( Ionic reaction )

សមាសធាតុអ៊ីយ៉ូនិចផ្តល់នូវអ៊ីយ៉ុងក្នុងភាពជាសូលុយស្យុង ដូច្នេះប្រតិកម្មគីមីអាចកើតឡើងយ៉ាងរហ័សពេលមានវត្តមាននៃអ៊ីយ៉ុងផ្សេងទៀត។

**ឧទា.12៖**

អ៊ីយ៉ុងស៊ុលហ្វាតវត្តមានក្នុងសូលុយស្យុងសូដ្យូមស៊ុលហ្វាត វាអាចបង្កើតជាកករយ៉ាងរហ័សពេលមានវត្តមានអ៊ីយ៉ុងបារ្យូមក្នុងបារ្យូមក្លរួ តាមលំនាំ៖

$$Na_2SO_4(s) \xrightarrow{H_2O} 2Na^+(aq) + SO_4^{2-}(aq)$$

$$BaCl_2(s) \xrightarrow{H_2O} Ba^{2+}(aq) + 2Cl^-(aq)$$

$$Ba^{2+}(aq) + SO_4^{2-}(aq) \rightarrow BaSO_4(s)$$



## ៦.វិធាន Fajan’s

### ៦.១.ភាពប៉ូលែកម្ម៖

- អាញ៉ុងដែលមានទំហំធំ និងមានបន្ទុកអវិជ្ជមានធំ,
- កាចុងដែលមានទំហំតូច និងមានបន្ទុកវិជ្ជមានធំ
- កាចុងដែលមានទម្រង់មិនដូចឧស្ម័នកម្រ
- ដង់ស៊ីតេបន្ទុកកាន់តែធំ ភាពប៉ូលែកាន់តែខ្លាំង

$$\text{Charge density}(C.mm^{-3}) = \frac{number\ of\ charge \times charge\ of\ proton\ (in\ coulombs)}{{}^4/_3 \times \pi \times (ion\ radius\ in\ mm)^3}$$

**៦.២. វិធាន Fajan’s ទី១**

សមាសធាតុដែលបង្កដោយកាចុងមានបន្ទុក 1+, 2+ និងកាចុងមានបន្ទុក 3+ ពេលផ្សំជាមួយអាញ៉ុងដែលមានភាពប៉ូលែកម្មខ្សោយជាសមាសធាតុអ៊ីយ៉ូនិច។

$Al + F_2$ ionic compound




$Al + Cl_2$ covalent compound




**ឧទា.13៖**

សមាសធាតុរបស់លោហៈក្រុម១ និងក្រុម២ សុទ្ធតែជាសមាសធាតុអ៊ីយ៉ូនិច ប៉ុន្តែអាលុយមីញ៉ូម ពេលផ្សំជាមួយភ្លុយអ័រ មានភាពប៉ូលែខ្សោយជាសមាសធាតុអ៊ីយ៉ូនិច ពេលផ្សំជាមួយក្លរ ប្រូមនិងអ៊ីយ៉ូដ ជាសមាសធាតុកូវ៉ាឡង់។

## ៦.៣. វិធាន Fajan's ទី២

អាញ៉ុងដែលមានទំហំតូចជាសមាសធាតុអ៊ីយ៉ូនិច និងមានចំណុចរលាយធំ
អាញ៉ុងដែលមានទំហំធំ ជាសមាសធាតុកូវ៉ាឡង់ និងមានចំណុចរលាយតូច

**ឧទា.14៖**

| សមាសធាតុ | ចំណុចរលាយ | បន្ទុកដង់ស៊ីតេ | ប្រភេទសម្ព័ន្ធ |
|---|---|---|---|
| ម៉ង់កាណែស(II)អុកស៊ីត | 1785 | 84 | Ionic bond |
| ម៉ង់កាណែស(III)អុកស៊ីត | | | Ionic bond |
| ម៉ង់កាណែស(VII)អុកស៊ីត | 6 | 1238 | Covalent bond |

## ៦.៤. វិធាន Fajan's ទី៣

កាចុង ក្នុងសមាសធាតុអ៊ីយ៉ូនិចមានទម្រង់ដូចឧស្ម័នកម្រ និងមិនមានទម្រង់ដូចឧស្ម័នកម្រជាសមាសធាតុកូវ៉ាឡង់។

**ឧទា.15៖**

ប៉ូតាស្យូមក្លរ កាចុងប៉ូតាស្យូមមានទម្រង់ $[Ar]^{18}$ និងប្រាក់ក្លរ កាចុងប្រាក់មានទម្រង់ $[Ar]^{18}3d^{10}$

KCl & AgCl

| | Z | $\lvert\chi_A-\chi_B\rvert$ | Configuration | ចំណុចរលាយ | ភាពរលាយ | សន្និដ្ឋាន |
|---|---|---|---|---|---|---|
| $K^+$ | 18 | $\lvert 0.82-3.16\rvert = 2.34$ | $1s^22s^22p^63s^23p^6=[Ar]$ | 770℃ | រលាយ | សមា. អ៊ីយ៉ុនិច |
| $Ag^+$ | 46 | $\lvert 1.93-3.16\rvert = 1.23$ | $1s^22s^22p^63s^23p^64s^23d^{10}4p^6$ | 455℃ | មិនរលាយ | សមា. កូវ៉ាឡង់ |

$Na_2O$ & $Cu_2O$

| | $\lvert\chi_A-\chi_B\rvert$ | 1st Fajan's | 2nd Fajan's | 3th Fajan's | ចំណុចរលាយ | សន្និដ្ឋាន |
|---|---|---|---|---|---|---|
| $Na_2O$ | $\lvert 0.93-3.5\rvert = 2.57$ | Ionic | Soluble | $[Ne]$ | 1132℃ | Ionic compound |
| $Cu_2O$ | $\lvert 1.9-3.5\rvert = 1.6$ | Ionic | Insoluble | $[Ar]3d^{10}$ | 1235℃ | Covalent compound |
| $Na_2S$ | $\lvert 0.93-2.5\rvert = 1.57$ | Ionic | Soluble | $[Ne]$ | 1176℃ | Ionic compound |
| $Cu_2S$ | $\lvert 1.9-2.5\rvert = 0.57$ | Ionic | Insoluble | $[Ar]3d^{10}$ | 1130℃ | Covalent compound |

$\lvert\chi_H-\chi_{Cl}\rvert = 2.2-3.16 = 0.96 < 1.9$ **covalent**

$\lvert\chi_A-\chi_B\rvert < 1.9$ covalent

$0.5 < \lvert\chi_A-\chi_B\rvert < 1.9$ covalent polar

$0 \le \lvert\chi_A-\chi_B\rvert \le 0.5$ covalent nonpolar

$Cu_2S \Longrightarrow$ *is covalents compound*

តាមនិយមន័យ វាជាសមាសធាតុអ៊ីយ៉ុនិច

តាមលក្ខខណ្ឌ $\lvert\chi_{Cu}-\chi_S\rvert = 0.57 < 1.9$ មិនមែនជាសមាសធាតុអ៊ីយ៉ុនិច

Fanjan 2 $Cu_2S$ insoluble

$Cu^+$: $[Ar]3d^{10}$



$SiF_4 \Longrightarrow$ *is covalents compound ???*

តាមនិយមន័យ វាជាសមាសធាតុកូវ៉ាឡង់ ☑

តាមលក្ខខណ្ឌ $\lvert\chi_{Si}-\chi_F\rvert = 1.9-4 > 1.9$ ជាសមាសធាតុអ៊ីយ៉ុនិច ☑

Fanjan 1 វាជាសមាសធាតុកូវ៉ាឡង់ ព្រោះ $Si^{4+}$ ☑

Fanjan 2 $SiF_4$ insoluble វាជាសមាសធាតុកូវ៉ាឡង់ ☑

$Si^{4+}$: $[Ne]$ ជាសមាសធាតុអ៊ីយ៉ុនិច

ចំណុចរលាយ −86℃ វាជាសមាសធាតុកូវ៉ាឡង់ ☑

$SiF_4 \Longrightarrow$ *is covalents compound*

$MgF_2 \Longrightarrow$ *is covalents compound or ionic???*

តាមនិយមន័យ វាជាសមាសធាតុអ៊ីយ៉ុនិច ☑

តាមលក្ខខណ្ឌ $\lvert\chi_{Mg}-\chi_F\rvert = 1.31-4 > 1.9$ ជាសមាសធាតុអ៊ីយ៉ុនិច ☑

Fanjan 2: $MgF_2$ soluble វាជាសមាសធាតុអ៊ីយ៉ុនិច ☑

Fanjan 3: $Mg^{2+}$: $[Ne]$ ជាសមាសធាតុអ៊ីយ៉ុនិច ☑

$MgF_2 \Longrightarrow$ *is ionic compound*

$SnCl_4 \Longrightarrow$ *is covalents compound ???*

តាមនិយមន័យ វាជាសមាសធាតុអ៊ីយ៉ុនិច

តាមលក្ខខណ្ឌ $\lvert\chi_{Sn}-\chi_{Cl}\rvert = 1.96-3.16 > 1.2$ ជាសមាសធាតុកូវ៉ាឡង់ ☑

Fanjan 1 វាជាសមាសធាតុកូវ៉ាឡង់ ព្រោះ $S_n^{4+}$ ☑

Fanjan 2 $SnCl_4$ soluble វាជាសមាសធាតុអ៊ីយ៉ុនិច

$Sn^{4+}$: $[Ne]$ ជាសមាសធាតុកូវ៉ាឡង់ ☑

ចំណុចរលាយ −34.07℃ វាជាសមាសធាតុកូវ៉ាឡង់ ☑

$SnCl_4 \Longrightarrow$ *is covalents compound*

## ៤. សម្ព័ន្ធកូវ៉ាឡង់

### ១. លក្ខណៈនៃការបង្កើតសម្ព័ន្ធកូវ៉ាឡង់

- អាតូមនឹងមិនមានការផ្ទេរអេឡិចត្រុងទៅឲ្យអាតូមមួយទៀតនោះទេ ប្រសិនបើកម្រិតអេឡិចត្រូអវិជ្ជមានរបស់ពួកវាស្មើសូន្យឬតូចបំផុត។

  $0.5 < |\chi_A - \chi_B| < 1.9$ is polar covalent bond

  $0 \leq |\chi_A - \chi_B| \leq 0.5$ is nonpolar covalent bond

- នៅពេលអាតូមទាំង ២ ដាក់អេឡិចត្រុងហ៊ុនគ្នាក្នុងការចងសម្ព័ន្ធជាមួយគ្នា អាតូម នីមួយៗត្រូវមាន ៨ អេឡិចត្រុងព័ទ្ធជុំវិញដូចទម្រង់ឧស្ម័នកម្រ

### ២. វ៉ាឡង់

វ៉ាឡង់ត្រូវបានបង្ហាញដោយអេឡិចត្រុងដែលដាក់ហ៊ុនគ្នា ដើម្បីឲ្យបានទម្រង់ដូចឧស្ម័នកម្រ ឬជាចំនួនសម្ព័ន្ធកូវ៉ាឡង់ដែលត្រូវបានបង្កើតអាតូមនៃធាតុគីមីមួយជាមួយអាតូមនៃធាតុគីមីមួយផ្សេងទៀត។

$\text{Valency of elements} = 8 - \textit{number of outer shell electron}$

| Elem. | N. Outer electron | 8 – group | Covalency | Elem. | N. Outer electron | 8 - group | Covalency |
|---|---|---|---|---|---|---|---|
| C | 4 | 8 – 4 = 4 | 4 | O | 6 | 8 – 6 = 2 | 2 |

អាចនិយាយម្យ៉ាងទៀតថា វ៉ាឡង់គឺ ជាចំនួនអេឡិចត្រុងសេរីនៅអ័រប៊ីតាល់ s និងអ័រប៊ីតាល់ p នៃអេឡិចត្រុងស្រទាប់វ៉ាឡង់( អេឡិចត្រុងស្រទាប់ក្រៅបង្អស់ )

ឧទា.16៖

អាតូម H មានវ៉ាឡង់ (I) ព្រោះមាន១អេឡិចត្រុងទំនេរ

អាតូម N មានវ៉ាឡង់ (III) ព្រោះមាន៣អេឡិចត្រុងទំនេរ

អាតូម O មានវ៉ាឡង់ (II) ព្រោះមាន២អេឡិចត្រុងទំនេរ

អាតូម Cl មានវ៉ាឡង់ (I) ព្រោះមាន១អេឡិចត្រុងទំនេរ







សណ្ឋានភ្ញោចទី១

សណ្ឋានភ្ញោចទី២

សណ្ឋានភ្ញោចទី៣





## ៣. លក្ខណៈទូទៅនៃសមាសធាតុកូវ៉ាឡង់

### ក. លក្ខណៈរូប (Physical state)

នៅលក្ខខណ្ឌធម្មតានៃសីតុណ្ហភាពនិងសំពាធ ម៉ូលេគុលនិងសមាសធាតុកូវ៉ាឡង់ជា ឧស្ម័នឬធាតុរាវមានចំណុចរំពុះទាប នេះបណ្ដាលពីកម្លាំងទំនាញខ្សោយរវាងម៉ូលេគុល។ ចំពោះម៉ូលេគុលដែលមានម៉ាសធំ ដូចជា ស្ពាន់ធ័រ ផូស្វ័រ អ៊ីយ៉ូដជាអង្គធាតុរឹង តែទន់។

### ខ. ចំណុចរលាយនិងចំណុចរំពុះ

លើកលែងតែម៉ូលេគុលធំ ដូចជា ពេជ្រ( Diamond ) កាបូរុន( Carborundum (SiC) ) ស៊ីលីកាត( $SiO_2$ ) ក្រៅពីនោះមានចំណុចរលាយនិងចំណុចរំពុះទាប។

### គ. ទម្រង់ក្រាម

- ប្រភេទទី១៖ ដូចជាស្ពាន់ធ័រ ផូស្វ័រ អ៊ីយ៉ូដប៉ង់តាអុកស៊ីត ងាយស្រួលឆេះវារងនូវកម្លាំង
- ប្រភេទទី២៖ វារួមបញ្ចូលទាំងស្រទាប់ក្រាម ដែលបំបែក។

